KhmerPost USA

Advertising: PA/NJ/NY: (267) 253-3947/ CT: (860) 461-3687
MA/RI: (978) 656-8141/ (781) 244-0522

មាតិការឿង | Vol 06 Issue 121 Jan. 11th- 24th. 2013 | ទំព័រ

១-សូមសួរសាលាក្រុងឡូវែលពីរបីសំណួរ.....០៤
២-អ្នកនយោបាយស៊ើរភ្លើង"សួង សុភ័ណ្ឌ"ខ្នាក់ហើយ.....០៥
៣-ក្លូបូលវិតណេសរាយការណ៍.....០៧
៤-សុខភាព និងម្ហូបអាហារយើង.....០៨
៥- អ្នកមានទិងអ្នកក្រនៅប្រទេសខ្មែរ.....០៩
៦-ភ្នំសំពៅ បង្អប់ដោយជំនឿបែប.....១០

32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us

# អនុវិទ្យាល័យ ឆាទ័រ នៃក្រុងឡូវែលនឹងចាប់កំណើត

**ខ្មែរផុស ស.រ.អា**

តំណាងសហគមន៍ខ្មែរ និងបរទេស៩នាក់ដឹកនាំដោយលោក វ៉ាស្នា នួន ជាគណក្រុមប្រឹក្សាសាលាក្រុងឡូវែល បានស្ដាប់អត្ថាធិប្បាយពីគម្រោងដំណើរការ អនុវិទ្យាល័យ ឆាទ័រ មួយដែលនឹងត្រូវបើកទ្វារនៅខែកញ្ញា ឆ្នាំ២០១៣ នៅចំកណ្ដាលក្រុងដែលសម្បូរខ្មែររស់នៅជាងគេនាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកនេះ កាលពីថ្ងៃចន្ទ កន្លងទៅនេះ ។ លោក រ៉ូប៊ឺត ជដាណូ ជា

តទៅទំព័រទី ១០



# បុណ្យសពលោក ឡឹក សំអឿន

**ពិន សំខុន**



ភ្ញៀវជាញាតិផៅ និងមិត្តភក្រ្គអ្នកធ្លាប់ស្គាល់ប្រមាណ១០០នាក់ បានមកជួបជុំគ្នាធ្វើបុណ្យសពលោក ឡឹក សំអឿន ដែលរលត់ជីវិតនៅថ្ងៃទី១៨ ធ្នូ២០១២ ក្នុងជន្មាយុ៨៥ ឆ្នាំ នៅវត្តត្រៃរតនារាមខាងលើ កាលពីថ្ងៃទី២៨ និង ២៩ធ្នូ កន្លងទៅ ។

លោក ឡឹក សំអឿន រស់នៅយ៉ាងស្ងៀមស្ងាត់នា៥-៦ឆ្នាំ ចុងក្រោយនេះ នៅក្រុងឡូវែល ដើម្បីសរសេរការចងចាំនៃដំណើរជីវិតដ៏សកម្មរបស់គាត់ជាមួយភរិយាឈ្មោះ ឡឹក ធិមមករា




កូនស្រីឈ្មោះ បូរី ណេត និងកូនប្រុសឈ្មោះ ខេមរា (បួសមុខភ្លើង ដើម្បីសងគុណឪពុកតាមគន្លងព្រះពុទ្ធសាសនា) ។

លោក ឡឹក សំអឿន បានត្រូវគេសម្គាល់ជាប្រវត្តិសាស្រ្តថា បានដឹកនាំចលនាប្រឆាំងសម្ដេចនរោត្តម សីហនុ តាំងពីឆ្នាំ១៩៥២ រហូតមកដល់ឆ្នាំ១៩៧០យ៉ាងចេញមុខពីព្រំប្រទល់ដែនខ្មែរ-ថៃ ភាគខាងជើង ។ លោក ប៉ែន ប៉េរ៉េ ដែលជាមិត្តជិតស្និទ្ធម្នាក់ហើយដែលបានសន្ទនា តទៅទំព័រទី ០៦





ភ្ជាប់ទៅកាន់ប្រទេសកម្ពុជា
នារដូវរងានេះក្នុងតម្លៃកាន់តែទាប
world tv
បន្តភ្ជាប់ទៅកាន់ប្រទេសកម្ពុជានារដូវរងានេះជាមួយ WorldTV ។ មើលប្រដាល់គុនខ្មែរ បទចម្រៀងល្បីៗ និងការសម្តែងតន្ត្រីបន្តផ្ទាល់តាមកម្មវិធីតន្ត្រីសម័យថ្មី ភាពយន្ត ព័ត៌មាន និងច្រើនទៀតនៅលើទូរទស្សន៍ CTN និង TVK ។
សូមមកទទួលនូវការជាវចំនួន 3 ខែជាមួយទូរទស្សន៍
CNT និង TVK
INTERNATIONAL
TVK
កញ្ចប់ផ្កាយរណប
WorldTV
(មានតម្លៃ $154)
ការដាក់ឱ្យដំណើរការ
ទទួលបានជិត 100
ប៉ុស្តិ៍ផ្សាយដោយឥតគិតថ្លៃ
ទាំងអស់ត្រឹមតែ
$175
ការផ្តល់ជូនបញ្ចប់នៅថ្ងៃទី 31 ខែ មករា ឆ្នាំ 2013 ។
សូមទូរស័ព្ទមកលេខ 1.888.802.8150 និងបញ្ជាក់អំពី
លេខកូដការផ្សព្វផ្សាយលេខ 53D នាថ្ងៃនេះ!
ឬចុះឈ្មោះតាមរយៈ:
WWW.GLOBECASTWTV.COM/HOLIDAY
ជួបយើងខ្ញុំតាម : WorldTV International Television : @WorldTVUSA

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL
ELDER CARE
978-596-111





## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្ដៅមួយដែលផ្ដល់សេវាមានកម្មវិធីជាកំលាក់ដល់សហគមន៍អ្នកគោរពបំណាង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គមកិច្ច កម្មវិធីរបស់យើង និងធានាឲ្យបាននូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## មណ្ឌលផ្ដល់នូវសេវាដូចតទៅ :

-មធ្យោបាយធ្វើដំណើរទៅវិញទៅមកពីផ្ទះរបស់អ្នក
-ការពិនិត្យ និងថែទាំសុខភាព
-ការព្យាបាលតាមរយៈការហាត់ប្រាណ
-កិច្ចការសង្គម ( ផ្ដល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ )
-អាហារខ្មែរក្ដៅៗ ពេលបាយ និងក្រៅពេលបាយ
-ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
-កម្មវិធីសិល្បៈ និងតន្ត្រី
-កម្មវិធីសិក្ខាសាលាអប់រំផ្សេងៗរៀងរាល់ថ្ងៃ
-ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន និងការសំណេះសំណាលគ្នា
-សេវាគាំពារ និងព្យាបាលជំងឺជើង
-សកម្មភាពក្រៅមណ្ឌល និងដំណើរកំសាន្តសប្បាយផ្សេងៗ

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ស្រឡាងមានទំហំដល់ទៅ១១000 Square foot ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មណ្ឌលយើងមានកន្លែងទទួលទានអាហារស្អាត និងមានពន្លឺ គ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សំរាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

45 Chelmsford St. Lowell, MA 01851
978-596-1111 – www.lowelleldercare.com



# APSARA WIRELESS

ទើបបើកថ្មី !

GRAND OPENING

285 Chelmsford St. Lowell, Ma 01851
Phone: (978)-455-0075
និយាយភាសាខ្មែរ: (978)-876-2875



▸ មានលក់ Sale
▸ ផ្ដល់សេវា Service
▸ ជួសជុល Repair

ទូរស័ព្ទ WIRELESS •កុំព្យូទ័រ •ឡាបថប •បរិក្ខាទូរស័ព្ទ •បង់ថ្លៃប៊ីល (Bill Pays)

សូមទៅមើលកន្លែងផ្សេងទៀត Location II: Happy Computer Service
122 Merrimack Street. Lowell, MA 01852 / ទូរស័ព្ទ: (978) 970-1769

# Cambodian Americans in Lowell would like to ask the city a couple of questions!

**By Sengly Kong**




The development of Cambodia Town of Lowell requires that community members of all walks of life participate in the development processes, the policy making and policy implementation. There are at least 200 businesses that are operated by Cambodian Americans in Lowell. These businesses include, but definitely are not limited to, jewelry stores, Khmer food restaurants, auto/home insurance agencies, grocery stores or supermarkets, liquor stores, electronic shops that repair and sell electronic gadgets, auto-mechanics that both repair and sell used cars etc. These economic operators and businesses have been significantly contributing to turning many formerly blighted and abandoned areas that were once refuges for many illicit and criminal activities into a vibrant economic district, a significant tax base for the city, a Southeast Asian cultural district in the New England, and most importantly, a sustainable source of jobs for thousands of community members.

Evidently Pailin Plaza was once blighted and a place where illicit drug dealing was taking place. Now it becomes a vibrant economic center with diverse economic activities, and Lowell City Council has designated this area as a Cambodia Town. Another area




on Chelmsford Street around Tepthida Khmer restaurant was also once blighted and dysfunctional; now it becomes a place of multiple services including restaurants, auto insurance agencies, law offices, and Asian food supermarket. Many residential areas where Cambodian Americans live were once abandoned and blighted; they were once places where criminal and illicit drug activities took place causing major concerns for

**Continue to Page 17**

# សូមសួរសាលាក្រុងឡូវែលពីរបីសំណួរ!

**ដោយ គង់ សេងលី**

ការអភិវឌ្ឍន៍ក្រុងខ្មែរឡូវែលទាមទារឱ្យមានការចូលរួមពីមហាជនគ្រប់ជាន់ថ្នាក់។ ក្រុងខ្មែរឡូវែលមានអាជីវកម្មខ្មែរមិនតិចជាង២០០កន្លែងឡើយ ។ អាជិវកម្មទាំងនោះរួមមានហាងលក់គ្រឿងអល័ង្ការ ភោជណីយដ្ឋានម្ហូបខ្មែរភ្នាក់




ងារលក់ធានារ៉ាប់រងរថយន្ត ហាងលក់គ្រឿងឧបភោគបរិភោគ ឬ ហាងគ្រឿងទេស ហាងលក់ភេសជ្ជៈគ្រប់ប្រភេទ ហាងលក់ និង ជួសជុលគ្រឿងអេឡិចត្រូនិច រោងជាងជួសជុល និងលក់រថយន្តគ្រប់ប្រភេទ។ អាជីវករ និង អាជីវកម្មទាំងនោះសុទ្ធតែបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រែក្លាយអតីតតំបន់បោះបង់ចោលដែលពោរពេញទៅដោយជំរកបទល្មើសគ្រប់ប្រភេទ ឱ្យទៅជាតំបន់ពាណិជ្ជកម្មរស់រវើកជាប្រភពចំណូលពន្ធដារដ៏សំខាន់ដល់សាលាក្រុង ជាទីក្រុងវប្បធម៌អាស៊ីអាគ្នេយ៍មួយនៅតំបន់ New England ជាពិសេសជាប្រភពផ្តល់ការងារមិនចេះរីងស្ងួតដល់ប្រជាពលរដ្ឋក្រុងឡូវែលរាប់ពាន់នាក់។ តំបន់ប៉ៃលិនផ្លាស្សា (Pailin Plazza) ធ្លាប់ជាកន្លែងអាគារបាក់បែកគ្មានប្រយោជន៍ប្រើប្រាស់ ឥឡូវក្លាយជាមណ្ឌលពាណិជ្ជកម្មច្រើនប្រភេទ។ តំបន់មុំភោជនីយដ្ឋានទេពធីតាក៏ធ្លាប់ជាកន្លែងអាគារបែកបាក់ បាត់បង់លទ្ធភាពប្រើប្រាស់ ឥឡូវក៏ក្លាយជាតំបន់អាជីវកម្មចំរុះ រួមមានភោជនីយដ្ឋានទេពធីតា ហាងទំនិញបាងកកដែលលក់គ្រឿងឧបភោគបរិភោគ និងគ្រឿងប្រើប្រាស់ច្រើនប្រភេទ។ តំនប់លំនៅស្ថានមួយចំនួនធំដែលប្រជាពលរដ្ឋខ្មែរអាមេរិកាំងរស់នៅសព្វថ្ងៃសុទ្ធសឹងជាកន្លែងផ្ទះបាក់បែកគ្មានមនុស្សរស់នៅ និងធ្លាប់ជាកន្លែងដោះដូរសារធាតុខុសច្បាប់ដែលធ្លាប់បង្កការបារម្ភណ៏ផ្នែកសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក៏ក្លាយជាតំបន់មនុស្សរស់នៅ ក្លាយជាមូលដ្ឋានផ្តល់ពន្ធដា (Property Tax ) ដ៏សំខាន់ដល់សាលាក្រុងឡូវែល ។

ថ្វីត្បិតតែយើងសំរេចបានជោគជ័យជាទីមោទនៈនេះ **តទៅទំព័រទី ០៦**






# អ្នកនយោបាយស្ទើរភ្លើង“ សួង សុភ័ណ្ឌ” ខ្លាក់ហើយលេបវិញ!

**ដោយ : អ៊ុំ លឿម**


អ៊ុំ លឿម

ក្នុងការចេញផ្សាយច្បាប់លេខ ១១៩ សម្រាប់ថ្ងៃទី០៨ ដល់ថ្ងៃទី ២០ ធ្នូ ឆ្នាំ២០១២ កន្លងមកនេះ“ខ្មែរផុស” បានចុះផ្សាយនូវព័ត៌មានរសើបមួយស្ដីពីប្រធានចលនាយុវជនគណបក្សសម រង្ស៊ី លោក សួង សុភ័ណ្ឌ ដាក់ពាក្យបណ្ដឹងប្ដឹងលោក ហ៊ុន សែន ពីបទមនុស្សឃាតគិតទុកជាមុនក្រោមចំណងជើង“ឆាកល្ខោននយោបាយរវាងលោក ហ៊ុន សែន និងយុវជនរបស់គណបក្សប្រឆាំងម្នាក់” ។ ព័ត៌មាននេះបានញ៉ាំងឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីមជ្ឈដ្ឋានក្រុមអ្នកតាមដានព្រឹត្តិការណ៍នយោបាយកម្ពុជា ។ ប៉ុន្ដែផ្ទុយទៅវិញ យុវជនរូបនេះ បានសម្រេចដកពាក្យបណ្ដឹងប្រឆាំងគូរបដិបក្សរបស់ខ្លួន គឺលោក ហ៊ុន សែន វិញ បន្ទាប់ពីពាក្យបណ្ដឹងនោះបានដល់ដៃតុលាការរាជធានីភ្នំពេញតែក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ។

ជាមួយសំណុំរឿងដ៏មហិមានេះ កាលពីថ្ងៃទី១៩ធ្នូកន្លងមកនេះ ព្រះរាជអាជ្ញារងអមតុលាការសាលាដំបូងរាជធានីភ្នំពេញលោក មាស ច័ន្ទពិសិដ្ឋ ក៏បានសម្រេចចេញដីការតម្កល់សំណុំរឿងក្ដីក្ដាំនេះ ដោយមិនចាត់ការលើពាក្យបណ្ដឹងប្រឆាំងលោក ហ៊ុន សែន ពីសំណាក់លោក សួង សុភ័ណ្ឌ ឡើយ ។

នាគ្រាកន្លងមកតាមរយៈការឆ្លើយសំនួរអ្នកកាសែត លោក សួង សុភ័ណ្ឌ បានអះអាងពីឆន្ទះមុះមុតរបស់ខ្លួនក្នុងការប្ដឹងលោក ហ៊ុន សែន ពីបទមនុស្សឃាតគិតទុកជាមុនដែលបានធ្វើឱ្យមនុស្សស្លាប់៣៥៣នាក់ និងរងរបួស៤០០នាក់នៅលើស្ពានកោះពេជ្រនាយប់ថ្ងៃបង្ហើយនៃពិធីបុណ្យអុំទូក កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១០ កន្លងមកនេះ ។ ក្នុងគ្រាដំណាលគ្នានោះដែរ លោក សួង សុភ័ណ្ឌ ក៏បានអះអាងបន្ដប្ដឹងទៅកាន់តុលាការយុត្តិធម៌នាប្រទេសហូឡង់ក្នុងទីក្រុងឡាអេនាពេលបន្ទាប់ ។

ជាមួយនឹងព្រឹត្តិការណ៍នយោបាយដ៏ច្របូកច្របល់នេះ ធ្វើឱ្យអ្នកគាំទ្ររបស់លោកនិងក្រុមអ្នកគាំទ្របក្សប្រឆាំងមួយចំនួនបានសម្ដែងនូវការខឹងសម្បារលាយឡំជាមួយនឹងការខកចិត្តយ៉ាងខ្លាំងចំពោះអ្វីដែលអ្នកនយោបាយស្ទើរភ្លើងរូបនេះបានធ្វើ ។ ពួកគេនាំគ្នានិយាយបែបចំអកថា“បើជ្រុលខ្លាក់ហើយ ម្ដេចឡើយលេបវិញ?” “ចុះបើមិនខ្លាចទេ, ម្ដេចខំប្រឹងលង?” ។

មែនទែនទៅអ្វីដែលអ្នកនយោបាយ“ផ្លែម្កាក់” សួង សុភ័ណ្ឌ បានធ្វើនាពេលកន្លងមកហាក់គ្មានឆន្ទៈប្ដឹងលោក ហ៊ុន សែន ដោយពិតប្រាកដឡើយ អ្វីដែលលោក សួង សុភ័ណ្ឌ បានធ្វើនោះ គឺគ្រាន់តែល្បិចនយោបាយដ៏រាក់ទាក់កំផែល ដើម្បីកេងសំណេញនយោបាយស្ទើរភ្លើងរបស់ខ្លួនតែប៉ុណ្ណោះ ។ លោក សួង សុភ័ណ្ឌ សុទិដ្ឋិនិយមថា ការធ្វើបែបនេះពិតជាទទួលបាននូវការគាំទ្រច្រើន និងមានការស្គាល់រូបលោកកាន់តែច្រើនពីសំណាក់ប្រជាពលរដ្ឋខ្មែរអ្នកជាតិ




និយមទាំងក្នុង និងក្រៅប្រទេស ប៉ុន្ដែផ្ទុយទៅវិញ សកម្មភាពនយោបាយ“បល់បាយ” របស់លោក សួង សុភ័ណ្ឌ បែរជាមានការខកចិត្តយ៉ាងខ្លាំងពីសំណាក់ក្រុមអ្នកគាំទ្ររបស់លោក ។

ជាការពិតណាស់ដែល“ឆាកល្ខោននយោបាយរវាងលោក ហ៊ុន សែន និងយុវជនរបស់បក្សប្រឆាំងម្នាក់”នោះគឺលោក សួង សុភ័ណ្ឌ ខ្លួនឯង ជាអ្នកនិពន្ធ ជាអ្នកដឹកនាំរឿង និងជាតួអង្គសម្ដែងខ្លួនឯង ហើយក៏ជាអ្នកបញ្ចប់ដោយខ្លួនឯង ។ ទស្សនិកជនជាច្រើនបានជក់ចិត្តដិតអារម្មណ៍ជាមួយ និងឆាកល្ខោននយោបាយរបស់លោក សួង សុភ័ណ្ឌ ណាស់ គេរង់ចាំមើលថា តើវានឹងបញ្ចប់ដោយវិធីណា? តើតួកាចឬតួស្លូតជាអ្នកឈ្នះ? ។ ប៉ុន្ដែផ្ទុយទៅវិញ ទស្សនិកជនដែលចំហរមាត់រង់ចាំមើលបែរជាមានការខកចិត្តយ៉ាងខ្លាំង ព្រោះឆាកល្ខោននោះត្រូវបានបញ្ចប់ដោយគ្មានន័យ និងពុំបានសម្ដែងពីសំណាងតួឯកទាំងពីរឡើយ ។

តាមការបកស្រាយរបស់លោក សួង សុភ័ណ្ឌ ក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់វិទ្យុជាភាសាខ្មែរនៅបរទេសមួយបានឱ្យដឹងថា: ការដែលលោកដកពាក្យបណ្ដឹងនេះ ព្រោះលោកជាមនុស្សដែលមានការគោរពនិងដើរតាមមាគ៌ារបស់ស្ដេច សីហនុ ។ មានន័យថាលោកគឺជាមនុស្សដែលស្រឡាញ់ស្ដេច សីហនុបំផុត ដូច្នេះលោកត្រូវតែស្ដាប់តាមព្រះបន្ទូលស្ដេចសីហនុដែលតែងតែមានបន្ទូលឱ្យខ្មែរគ្រប់ក្រុមគ្រប់បក្សមានការឯកភាពជាតិ និងរួបរួមគ្នាជាធ្លុងមួយ...។ ទាក់ទងនឹងការបកស្រាយបែបនេះត្រូវបានមតិមួយចំនួនសម្ដែងនូវការងឿងឆ្ងល់ថា: ចុះបើដឹងថា ចង់ឱ្យមានការឯកភាពជាតិមែនចាំបាច់ធ្វើខ្លាំងពីដំបូងហើយដាំដូងចុងក្រោយធ្វើអ្វី”? ។ នេះចំជាអ្នកនយោបាយផ្លែម្កាក់មែន ហ្ន៎! ៕


GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្ដល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វើរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH FOR KIDS
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

តមកពីទំព័រទី ១

## ពិធីបុណ្យសពលោក ឡឹក សំអឿន...


លោក ប៉ែន ប៉េល

ជាមួយលោក សំ អឿន រហូតដល់ផុតដង្ហើមថា "លោក ឡឹក សំអឿន ចេញពីសាលាមេព្រៃនៅឆ្នាំ១៩៥២ ហើយនៅឆ្នាំដដែលនោះ ជាមួយមិត្តភ័ក្តិមួយចំនួនក៏ចូលព្រៃកាន់អាវុធប្រឆាំងនឹងនយោបាយសម្តេចនរោត្តមសីហនុដែលបានដឹកនាំប្រទេសឱ្យចូលគន្លងកុម្មុយនីស្តដែលជានយោបាយអាក្រក់បំផុតចំពោះពលរដ្ឋដែលចង់បានសេរីភាព ។ លោកកាន់ទ័ពច្បាំងក្រោមបញ្ជាការលោក សឺង ង៉ុកថាញ់ រហូតដល់កម្ពុជាទម្លាក់សម្តេចសីហនុបានសម្រេចនៅឆ្នាំ១៩៧០ ហើយលោកក៏ចូលបំរើកងខេមរៈយោធាកម្ពុជា ដើម្បីវាយកុម្មុយនីស្តដែលវាយលុកកម្ពុជារហូតដល់សាធារណរដ្ឋខ្មែរចាញ់កម្លាំងកុម្មុយនីស្តឆ្នាំ១៩៧៥ ។

មុននឹងស្លាប់លោកនៅទន្ទេញប្រាប់លោក ប៉េរ៉េ ថា "ផ្តាំឱ្យខ្មែររួបរួមគ្នាស្រលាញ់គ្នាឡើងពួតដៃគ្នាទប់ទល់កុំឱ្យយួនយកទឹកដីបាន!" លោកស្រី ធិមមករា បាននិយាយថា "ក្នុងជីវិតរបស់ប្តីខ្ញុំមានតែការស្រលាញ់ជាតិតែមួយប៉ុណ្ណោះ រហូតដល់ថ្ងៃស្លាប់!" ។ បន្ទាប់ពីគោរពសព និងបូជារួចហើយ លោកស្រី ធិមមករា បាន




លោក ស្រី ខេមរា


ព្រះតេជគុណ សៅ ឃន និងភិក្ខុ ខេមរា


លោកស្រី បូរីណេត

អនុញ្ញាតិឱ្យខ្មែរផុសផ្សាយស្នាដៃរបស់លោក ឡឹក សំអឿន ហើយការលក់សៀវភៅ និងយកកំរៃពាក់កណ្តាលទៅជួយអ្នកក្រីក្រនៅកម្ពុជា ។

ព្រះតេជគុណ សៅ ខន ជាចៅអធិការនៅមណ្ឌលសហគមន៍ព្រះសង្ឃខ្មែរសហរដ្ឋអាមេរិកបានតែងកំណាព្យមួយអានកាលពីថ្ងៃសុក្រ ទី២៨ ខែ ធ្នូ គ.ស ២០១៣ នៅវត្តត្រៃរតនារាម ដើម្បីចូលរួមមរណទុក្ខជាមួយគ្រួសារលោក ឡឹក សំអឿន ហៅផ្កាយព្រឹក "សូមវិញ្ញាណក្ខន្ធរបស់លោកជួយបញ្ចុះបញ្ចូលចិត្តពុជសាសន៍ខ្មែរឱ្យមានសាមគ្គីឡើងវិញផង" ។

ព្រះសង្ឃ និងពុទ្ធបរិស័ទធ្វើបុណ្យវេចង្ហាន់ ក្នុងបរិយាកាសយ៉ាងត្រជាក់ស្មើរទ្រាំមិនបានដោយគ្មានម៉ាស៊ីនកំដៅគ្រប់គ្រាន់ -នេះជាលទ្ធផលនៃទំនាស់វត្តលើ-ក្រោម សំណាងល្អគ្មាននរណាម្នាក់ឈឺ ៕



## ក្តីគោរពសពលោក ឡឹក សំអឿន

( ពាក្យ៨ )

១-ខ្ញុំសូមវិន្ទា　អោនកាយគោរព　នៅចំពោះសព　លោកឡឹកសំអឿន
　វីរៈបុរសខ្មែរ　ក្លាហានជឿនលឿន　ចំបាំងច្រើនជាន់　ដេញទមិលប្ញស្សា ។
២-លោកបំរើជាតិ　មិនឃ្លាតត្រង់ណា　ការពារប្រជា　រំដោះទឹកដី
　កាន់ច្បាប់ត្រឹមត្រូវ　ដ៏សែនប្រពៃ　ជួយខ្មែរប្រុសស្រី　សព្វទីកន្លែង ។
៣-លោកពិតជាប្រុស　ដើមទ្រូងប្រាំហត្ថ　ក្លាយហានមោះមុត　គួរជាគំរូរ
　សម្រាប់កូនខ្មែរ　គ្រប់ទាំងមីងពូ　ជាអ្នកតស៊ូ　ត្រូវតែត្រង់ត្រាប់ ។
៤-វិរៈបុរសខ្មែរ　គឺមានតិចណាស់　តែលោកពិតច្បាស់　មួយដ៏ កម្រ
　លោកជាមេទ័ព　កងកន្សែងសរ　បុត្រខ្មែរអបអរ　គាំទ្រជានិច្ច ។
៥-កងទ័ពលោកខ្លាំង　កម្លាំងមហិមារ　មានជ័យរិទ្ធី　សព្វសមរភូមិ
　ដេញខ្មាំងបារាំង　ព្រមទាំងយួនផង　ដែលតែងបំពាន　ជិះជាន់ខ្មែរយើង ។
៦-លោកធ្វើទាហាន　មិនមានគ្រួសារ　ព្រោះទមិលប្ញស្សា　តែងប៉ងបំផ្លាញ
　រស់ជាកម្លោះ　តស៊ូស្វិតស្វាញ　គ្មានគិតអ្វីផ្សេង　ស្នេហាជាតិ ។
៧-លោកពិតស្អាតស្អំ　មិនស៊ីសំណូក　មន្ត្រីដូចជាលោកតិចណាស់
　មិនជិះជាន់គេ　ចង់មានរបស់　លោកពិតជាម្ចាស់　អ្នកស្នេហាជាតិ ។
៨-លោកមកស្រុកគេ　ទើបការប្រពន្ធ　ដែលមានទុក្ខធ្ងន់　ជាស្រីម៉ាយ
　ដោយក្តីស្នេហា　លោកបានចំណាយ　សព្វកម្លាំងកាយ　និងកម្លាំងចិត្ត ។
៩-លោកចារសៀវភៅ　នៅប្រវត្តិសាស្ត្រ　ដែលលោកដឹងច្បាស់　បានប្រព្រឹត្តមក
　សម្រាប់កូនខ្មែរ　ម្ចាស់ដីគោកធ្លក　គួរយេងលៃលក　ជាវថែរក្សា ។
១០-យើងខ្ញុំសូមលា　ជាលើកចុងក្រោយ　ព្រមយំដង្ហោយ　សែនស្តាយលោកណាស់
　ដែលចែកឋានទៅ　តែអង្គឯងម្នាក់　ចិត្តយើងអួលអាក់　លើសអធិប្បាយ ។

និពន្ធដោយលោក

**សូ ប៊ុនធឿន**

ថ្ងៃ ព្រហស្បតិ៍ ទី២១ ខែ ធ្នូ ឆ្នាំ២០១២



## គុណធម៌លោក ផ្កាយព្រឹក

គុ ណធមិល្អលោកផ្កាយព្រឹក　មានគុណអធិករាប់មិនបាន
សូមបងប្អូនខ្មែរយើងគ្រប់ប្រាណ　បណ្តុះឱ្យបានធមិខ្ពង់ខ្ពស់ ។
គុណធមិជាសេចក្តីល្អ　សម្រាប់ជួយកសាងជាតិមនុស្ស
ឱ្យបានសាមគ្គីឡើងខ្ពស់　សមជាមនុស្សខ្មែរប្រាកដ ។
ប្រែពីបៀតបៀនមកមេត្តា　ដូចផ្កាយព្រឹកណាខន្តីអត់
តែងផ្តល់គំនិតអ្នកក្រខ្សត់　កុំឱ្យគ្នាអត់ដឹងអីឡើយ ។
ទោះមិនសម្បូរណ៍ល្មមធនបាន　ទុក្ខរាស្ត្រស្រាកស្រាន្តបានស្រាយស្បើយ
ធូរទ្រូងគិតជាតិសុខល្ហែល្ហើយ　គុណធមិនេះហើយសាងសុខ ។
គុណធមិសាងជាតិខ្មែរបាន　លូតលាស់កើតកើនលឿនទៅមុខ
សម្បូរសប្បាយគ្រប់ភូមិស្រុក　មានតែក្តីសុខគ្រប់ៗគ្នា ។
គុណធមិនេះភ្លឺអស្ចារ្យ　ចំពោះពូជខ្មែររាស្ត្រប្រជា
នាំក្តីគ្នាសាងសួគ៌ា　ចេញចរយាត្រាដល់វិមាន ។
ហេតុនេះសូមបងប្អូនទាំងឡាយ　ខិតខំខ្វល់ខ្វាយគ្រប់ៗប្រាណ
លះក្តីអាក្រក់កុំបីខាន　បណ្តុះឱ្យបាននូវគុណធមិ ។
ពូជសាសន៍យើងបានថ្កោងឡើងវិញ　ញាតិមិត្តពោរពេញមូលកុះករ
យើងរស់រួមគ្នាដោយស្មោះសរ　ថ្លៃថ្លាបវរអង្វែងទៅអើយ ! ។

**ដោយព្រះតេជគុណ សៅ ឃន**

តមកពីទំព័រទី ៤

## សូមសួរសាលាក្រុងឡូវែល...

សហគមន៍ខ្មែរឡូវែលនៅមានបញ្ហាប្រឈមចាស់ថ្មីមួយចំនួនទៀតដែលរារាំងដល់ការសំរេចបាននូវសក្តានុពលភាពអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចនៅសហគមន៍។ ការរួមតូចនៃមូលដ្ឋានអតិថិជន ឬ Shrunken customer base or market share បាននិងកំពុងចោទជាបញ្ហាដល់អាជីកម្មមួយចំនួន។ បញ្ហានេះកំរូវឱ្យមានការដោះស្រាយជាបន្ទាន់ បើមិនដូច្នោះអាជីវកម្មទាំងនោះអាចប្រឈមនឹងការក្ស័យធន់។ ការដោះស្រាយទាមទារឱ្យមានការចូលរួមទាំងអាជីវករ និងសមត្ថកិច្ចសាលាក្រុងឡូវែល។ ការរួបរួមរបស់អាជីវករនឹងផ្តល់សំពាធនយោបាយច្រើនក្នុងការជំរុញឱ្យសមត្ថកិច្ចក្រុងផ្តល់អាទិភាពដល់ការអភិវឌ្ឍន៍ក្រុងឡូវែលនៅគោលនយោបាយយុទ្ធសាស្ត្ររបស់ខ្លួន ។ អាជីវករអាចចូលរួមតាមរូបភាពជាច្រើនយ៉ាង។ គាត់អាចឆ្លៀតពេលចូលរួមការប្រជុំក្រុមប្រឹក្សាក្រុង ដើម្បីជំរាបជូនសមាជិកាក្រុមប្រឹក្សាក្រុងអំពីសំណូមពរដែលអាជីវករសាមុីនីមួយៗជួបប្រទះ ក៏ដូចជាសំណូមពររួមរបស់សហគមន៍ទាំងមូល។ គាត់អាចចូលរួមតាមរយៈញ្ញតិទាមទារបញ្ជូនទៅសមាជិកក្រុមប្រឹក្សាក្រុង ដើម្បីពិចារណា និងសម្រេចដោះស្រាយសំណូមពររបស់គាត់ក៏បាន។

គាត់អាចមានសំណូមពរឱ្យមានការពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការសំអាតអនាម័យសាធារណៈ ការលើកកំពល់សោភណ្ឌភាពបរិស្ថានក្រុង ការកែសំរួលនយោបាយពន្ធដា ការកែសម្រួលនយោបាយតំបន់ពាណិជ្ជកម្ម ។ល។ ទាក់ទង់នឹងការបង្កើនសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ យើងអាចទាមទារឱ្យមានសមត្ថកិច្ចក្រុងដាក់ប្រព័ន្ធត្រួតពិនិត្យបទឧក្រិដ ឬចោរកម្មនៅតាមមណ្ឌលពាណិជ្ជកម្ម អាជីវកម្មខ្មែរសំខាន់ៗដូចជា Branch Street and Cupple Square area ។ ការដាក់ឱ្យមានប្រព័ន្ធសន្តិសុខស្វ័យប្រវត្តិនេះនឹងកាត់បន្ថយលទ្ធភាព ឬទប់ស្កាត់បទឧក្រិដ្ឋចោរកម្មដែលអាចកើតឡើងជាយថាហេតុបានមួយចំនួនក៏រិតធំ។ ស្ថានភាពវិជ្ជមាននេះអាចកាត់បន្ថយតម្លៃធានារ៉ាប់រងអាជីវករត្រូវបង់ក្នុងការបើកបររកស៊ីរបស់គាត់ និងអាចទាក់ទាញវិនិយោគគិនថ្មីៗមកបណ្តាក់ទុនរកស៊ីថែមទៀតនៅទីក្រុងរបស់យើង ។ មិនតែប៉ុណ្ណោះសន្តិសុខនិងសណ្តាប់ធ្នាប់បរិបូរណ៏អាចកាត់បន្ថយហានិភ័យពាណិជ្ជកម្ម (Business Risks) ធ្វើឱ្យតម្លៃប្រាក់កម្ចីមានក៏រិតទាបល្មមដែលអាចលើកទឹកចិត្តឱ្យមានការបណ្តាក់ទុរកស៊ី និងបង្កើតការងារថ្មីៗថែមទៀតនៅក្នុងក្រុង។

ស្ថានភាពវិជ្ជមានទាំងនោះ អាចកើទឡើង

តទៅទំព័រទី ១៥

# សុខភាព និងម្ហូបអាហារយើងបរិភោគ

## អ្នកឧបត្ថម្ភ

Serves 5
Serving size: 3 skewers (3 ounces cooked meat total per person)

### *Preparation*

Pound the sliced beef with a meat hammer until it is tender.

Grind the ingredients for the paste in a grinder or blender or pound them with a mortar and pestle until they make a fine paste. Mix in the oil, sugar, salt, and lime juice. Add the meat to the paste and mix well to coat. Marinate at least 1-2 hours in the refrigerator.

Put the meat onto the skewers, and cook on a grill or broil to medium done, about 3-5 minutes per side. Spread on a serving plate and sprinkle with peanuts.

### *Nutrition Notes*

- Reduced sodium (less salt)
- Reduced saturated fat and cholesterol (lean beef instead of higher-fat cut)



## សាច់មាន់អាំង

### គ្រឿងផ្សំ

- ទឹកស៊ីអ៊ីវដែលមានជាតិ សូឌីយ៉ូមតិច ៣ ស្លាបព្រា
- ទឹក ១ ស្លាបព្រា
- ស្ករ ១ ស្លាបព្រា
- ខ្ទឹមស ៤ កំពីសចិញ្ច្រាំល្អិតៗ
- ប្រេងកាណូឡា ១/២ ស្លាបព្រា
- ម្រេចកិនថ្មីៗ ១ ស្លាបព្រា

រៀបចំសំរាប់មនុស្ស : ៦ នាក់
បរិមាណបរិភោគ : ជើងមាន់ទាំងមូល (កំភួនជើង និង ភ្លៅ) ឬកំភួនជើង២ ឬភ្លៅ២

**ការរៀបចំ :**

លាយទឹកស៊ីអ៊ីវ, ស្ករ, ខ្ទឹមស, ប្រេង, ម្រេច និងអំបិល ចូលគ្នា ។ ប្រឡាក់សាច់ភ្លៅមាន់ ហើយផ្អាប់ទុកយ៉ាង ហោចណាស់មួយម៉ោង ដើម្បីឲ្យសាច់ចូលជាតិល្អ ។

អាំងសាច់ភ្លៅមាន់នៅក្នុងចង្ក្រានអាំងប្រហែល ១៥-២០ នាទីក្នុងមួយចំហៀង ។ បើសិនប្រើចង្ក្រានធ្យូង សូមដាក់ឲ្យឆ្ងាយពីអណ្តាតភ្លើងបន្តិចដើម្បីកុំឲ្យខ្លោច ។ បើសិនចង្ក្រានឧស្ម័ន ប្រើភ្លើងល្មម ។ បើសិនអាំងលើចង្កើរ, សូមប្រែឲ្យបានញឹកញាប់បន្តិច ដើម្បីជៀសវាងខ្លោច និងជាប់ស្អិត ។

### កំណត់សំគាល់អាហារូបត្ថម្ភ

- បន្ថយជាតិសូឌីយ៉ូម (ប្រើទឹកស៊ីអ៊ីវមានជាតិសូឌីយ៉ូមតិច, កុំប្រើអំបិល)
- បន្ថយជាតិខ្លាញ់ឆ្អែត និងជាតិកូលេស្ទ័រោល (ប្រើភ្លៅមាន់បកស្បែកចេញ)
- ទាំងនេះបង្កើតឲ្យមានរសជាតិឆ្ងាញ់ ព្រមទាំងមានស្រក់ខ្លាញ់ពេលអាំងនៅលើចង្ក្រានឧស្ម័នក្នុងកម្រិតកំដៅមធ្យម ។ ត្រូវឧស្សាប្រែចុះឡើងឲ្យ



## *Grilled Chicken*

### *Ingredients/Shopping list*

3 tablespoons reduced sodium soy sauce
1 tablespoon water
1 tablespoon sugar
4 cloves garlic, chopped
½ tablespoon canola oil
1 teaspoon fresh ground pepper
6 skinless chicken legs (on bone, both drumsticks and thighs) OR 12 of either

Serves 6
Serving size: 1 whole leg (drumstick and thigh) or 2 drumsticks or 2 thighs

### *Preparation*

Combine soy sauce, sugar, garlic, oil, and pepper. Marinate the chicken for at least 1 hour. Broil the chicken on the middle rack of the oven, or on a hot grill, about 15-20 minutes per side. If cooking on a charcoal grill, place the chicken far enough away from the heat that the chicken does not burn. If using a gas grill, use medium-low heat. If cooking on a grill, turn frequently to prevent burning and sticking.

### *Nutrition Notes*

- Reduced sodium (reduced sodium soy sauce, no salt)
- Reduced saturated fat and cholesterol (skinless chicken legs and thighs)
- These came out very tasty and juicy when cooked on a gas grill on medium-low heat. The trick is to turn them often, so that the meat cooks evenly but the outer (skinless) layer does not burn.



## នំបញ្ចែវ

### គ្រឿងផ្សំ

- សាច់ស្ងួលបាញ់ឆែវ
- ប្រេងកាណូឡា ១ ស្លាបព្រា
- ខ្ទឹមស ១ កំពីសចិញ្ច្រាំឲ្យល្អិត
- ខ្ទឹមបារាំង ១ មើមតូចល្មមហាន់ល្អិតៗ
- សាច់ភ្លៅមាន់ ១ ភ្លៅចិញ្ច្រាំឲ្យល្អិតៗ
- អំបិល ១/៨ ស្លាបព្រា

បន្លែ

- ត្រសក់ ៣ ផ្លែ
- ស្លឹកជីរក្រហម ១ កែវ
- ជីរថ្ពាល់ត្រី ១ កែវ
- ជីរអង្កាម ១ កែវ
- ម្ទេស ៥-៦ ផ្លែ
- សាឡាត់ ១ គុម្ព

ម្សៅបញ្ចែវ

- ម្សៅអង្ករ ៣ កែវរង្វាល់
- ម្សៅរមៀត ១.៥ ស្លាបព្រា
- ម្សៅដំឡូងឈើ ១ ស្លាបព្រា
- ស៊ុតមាន់ ១
- សណ្តែកបណ្តុះ ១០ អោនស៍

រៀបចំសំរាប់មនុស្ស : ៦ នាក់
បរិមាណបរិភោគ : នំបញ្ចែវ ២ បន្ទះ

**ការរៀបចំ :**

សាច់មាន់យកសាច់ដែលកិនស្រាប់ ឬចិញ្ច្រាំខ្លួនឯងក៏បាន, ខ្ទឹមបារាំងហាន់ឲ្យស្តើង ។ ស្នួលនំបញ្ចែវអាចធ្វើពីសាច់បង្គង, ព្រោន និងសាច់ជ្រូកក៏បាន ស្រេចតែមនុស្សម្នាក់ៗនិយម ។

កម្លោចខ្ទឹមស ។ ដាក់សាច់មាន់ និងអំបិលចូល ។ ចំអិនសាច់មាន់ទាល់តែជិតឆ្អិន, កូរជាញឹកញាប់, បន្ទាប់មកដាក់ខ្ទឹមបារាំង ។ ខ្ទឹមបារាំងគួរតែនៅស្រួយច្រូបៗបន្តិចនៅពេលចុងក្រោយ ។

លាងបន្លែ និងជីរទាំងអស់ឲ្យបានស្អាត ។ ចិតសំបកត្រសក់ ហើយចិតបញ្ឆិតស្តើងៗ ។ រៀបចំចានសំប៉ែតធំដោយបំបែកស្លឹកសាឡាត ហើយដាក់វានៅជុំវិញជាយ និងនៅចំកណ្តាលចាន ដើម្បីជាទ្រនាប់ខាងក្នុង ។ រៀបចំណិតត្រសក់ដាក់ជុំវិញចានសំប៉ែតធំនោះ ហើយដាក់ជីរក្រហមនិងជីរផ្សេងទៀតក្នុងគំនរនៅចំកណ្តាល ។

ដើម្បីធ្វើនំបញ្ចែវ, វាយស៊ុតសព្វល្អ, បន្ទាប់មកលាយជាមួយម្សៅអង្ករ, រមៀត, ម្សៅដំឡូង និងទឹកដើម្បីលាយវាឲ្យរាវ ។ កម្តៅខ្ទះឲ្យក្តៅល្មម ។ បាញ់ប្រេងកំប៉ុងម្យ៉ាងដើម្បីកុំឲ្យបាតខ្ទះជាប់ បន្ទាប់មកចាក់ពង្រាយម្សៅដែលលាយរួចហើយប្រហែលមួយភាគបួន ទៅមួយភាគបីពែងនៅក្នុងខ្ទះក្តៅ, ដំបូងចាក់ម្សៅនៅជាយខ្ទះ ហើយផ្អៀងខ្ទះចុះឡើងដើម្បីឲ្យម្សៅរាយស្តើងស្មើនៅក្នុងបាតខ្ទះ ។ គ្របខ្ទះឲ្យជិតដើម្បីកុំឲ្យខ្យល់ចេញចូលក្នុងខ្ទះ ។ ចំអិនប្រហែល ២-៣ នាទី ទាល់តែម្សៅខាងជាយចាប់ផ្តើមស្រួយ ហើយជាយៗរបើកចេញពីខ្ទះ បន្ទាប់មកដាក់សាច់មាន់ដែលលាយរួចហើយ ប្រហែលមួយភាគបួនពែង និងដាក់សណ្តែកបណ្តុះមួយភាពបួនពែងដែរ ។ គ្របហើយចំអិនប្រហែល ២-៣ នាទីទៀតទាល់តែសណ្តែកបណ្តុះចាប់ផ្តើមទន់ល្មម ។ បត់នំបញ្ចែវពាក់កណ្តាល ហើយដាក់ចូលក្នុងចាន រួចហើយយកក្រដាសអាលុមមីនយ៉ូមដាក់ពីលើដើម្បីកុំឲ្យជាប់ ។ បើសិនម្សៅ

## *Happy Pancakes*

### *Ingredients/Shopping list*

*Meat Filling*
1 tablespoon canola oil
1 clove garlic, finely chopped
1 medium onion, thinly sliced and quartered
1 pound ground chicken or ground turkey
(in the poultry section at the store)
⅛ teaspoon salt

*Vegetables*
3 cucumbers
1 cup basil leaves, packed
1 cup fish mouth herb, packed
1 cup ma kaa herb, packed
1 cup san kro hom herb, packed
5-6 bird's eye chili peppers, stems removed
1 head leaf lettuce, such as red leaf

*Pancake*
3 cups rice flour
1½ teaspoons turmeric
1 teaspoon tapioca starch
1 egg
2¼ cups water

10 ounces mung beans (about 2½ cups)

Serves 6
Serving size: 2 pancakes

### *Preparation*

Brown the garlic in the oil. Add the chicken or turkey and salt. Cook until the chicken is almost done, stirring frequently, then add the onions. The onions should still be a little crunchy when finished.

Wash all the vegetables and herbs well. Peel the cucumbers and slice very thinly diagonally. Prepare a platter by separating the leaves of the lettuce and placing the leaves around the edges and center of a platter, as a lining. Arrange the sliced cucumbers around the platter, and place the basil and other herbs in piles in the center. Sprinkle the chilies near the corners of the platter.

To make the pancake, beat the egg, then mix with the rice flour, turmeric, tapioca starch, and water into a thin batter. On medium-high, heat a wide-bottomed wok or large frying pan with large bottom (at least 10-12 inches wide). Spray with nonstick cooking spray. Spread about ¼ to ⅓ cup of the batter in the hot pan, pouring first on the edges, and tilting the pan so that the batter is spread out thinly and covers the bottom. Cover the pan tightly. Cook for 2-3 minutes, until the outer edges start to be crispy and the edges lift slightly from the pan, then add about ¼ cup of the chicken mixture and ¼ cup of mung bean sprouts. Cover

តទៅលេខក្រោយ

# អ្នកក្រនិងអ្នកមាននៅប្រទេសខ្មែរ ភាគទី៣


គីម សុស មន្ត្រីចូលនិវត្ត ក្រសួងការបរទេស សហរដ្ឋអាមេរិក

**ដោយ គីម សុស**

បើតាមការជម្រាបជូនតាំងពីដើមមកដល់ពេលនេះ ហើយនឹងបើតាមប្រសាសន៍របស់លោកប៉ែនបូណាអ្នកសារពត៌មាននៃវិទ្យុបារាំងអន្តរជាតិ (RFI) ផ្សាយចេញនៅថ្ងៃសៅរ៍២៩ធ្នូ ២០១២នោះថា "សម្រាប់ឆ្នាំថ្មីឆ្នាំសាកល២០១៣ ដែលនឹងចូលមកដល់ក្នុងរយៈពេល៣ថ្ងៃខាងមុខប្រជាពលរដ្ឋខ្មែរក៏មានក្តីប្រាថ្នារបស់ខ្លួនដែរ ។ ក្តីប្រាថ្នាមួយក្នុងចំណោមក្តីប្រាថ្នាជាច្រើនរបស់ពួកគេគឺការចង់ឃើញភាពសុខដុមរមនានៅក្នុងឆាកនយោបាយ។ ប៉ុន្តែភាពស្មុគស្មាញខាងនយោបាយនៅក្នុងឆ្នាំចាស់នេះគឺជាសញ្ញាដែលក្រុមអ្នកតាមដានស្ថានការណ៍ប្រទេសកម្ពុជាមើលឃើញថា វាហាក់ដូចជាពិបាករំពឹងណាស់ថា សភាពការណ៍នយោបាយក្នុងឆ្នាំ២០១៣ មានសភាពធូរស្រាល"។ ខ្ញុំបារម្ភថា សង្គមខ្មែរនឹងអាចមានបញ្ហាដែលនាំមកនូវក្តីមហន្តរាយមកដល់ប្រទេសនៅពេលណាដែលចិត្តគំនិតរបស់មនុស្សចំនួនជាង១១លាននាក់នេះអាចនឹងត្រូវបង្រួបបង្រួមគ្នាឱ្យទៅជាធ្លុងមួយបាន ដើម្បីនឹងប្រឆាំងនឹងអ្វីមួយដែលធ្វើឱ្យគេកើតទុក្ខវេទនាទ្រាំមិនបាន។

ដើម្បីឱ្យងាយយល់ ហើយនឹងឱ្យបានច្បាស់នូវមហន្តរាយដែលអាចកើតឡើងនៅពេលខាងមុខនោះទៅទៀតនោះ យើងអាចប្រៀបធៀបប្រជាពលរដ្ឋខ្មែរទាំងមូល គឺប្រមាណជិត១៥លាននាក់នេះនឹងព្រៃឈើមួយដំដែលមានដើមឈើធំៗ ហើយខ្ពស់ៗប្រមាណ២០ភាគរយដុះក្នុងចំណោមកូនឈើតូចៗ វល្លិ និងស្មៅដែលរួមមានចំនួន៨០ភាគរយនៃព្រៃឈើទាំងមូលនោះទៀត ដុះប្រជ្រៀតគ្នាកកកុញមានទាំងដើមមែកស្លឹកពុកងាប់ស្ងួតក្រាលក្រាស់ដេរដាសលើដី ។ គួរគិតមើលនៅថ្ងៃមួយមានអ្នកណាមួយចោលកន្ទុយបារីដែលនៅមានភ្លើងទៅលើព្រៃនោះ ឬក៏រន្ទះភ្លើងបាញ់មកលើព្រៃនោះព្រៃទាំងមូលនោះនឹងអាចឆេះខ្ទេចអស់បាន។ សុំកុំភ្លេចថា មនុស្សក្នុងចំណោម៨០ភាគរយនោះកំពុងនៅក្នុងធមិក្តៅក្រហាយមកពីក្តីមិនសប្បាយចិត្តនឹងជីវិតរស់នៅរបស់ខ្លួន។

តែផ្ទុយទៅវិញ សង្គមនឹងទទួលនូវសេចក្តីរុងរឿងចំរុងចំរើននៅពេលណាដែលមានគំនិតមួយដែលអាចដឹកនាំចំនួនមនុស្ស១១លាននាក់នេះឱ្យទៅជាធ្លុងមួយដើម្បីធ្វើអ្វីមួយដែលសង្គមទាំងមូលត្រូវការ។

ដូច្នេះរឿងសំខាន់ ដើម្បីដោះស្រាយបញ្ហាដែលអាចនឹងកើតមាននៅក្នុងសង្គមខ្មែរនៅពេលខាងមុខយើងត្រូវរកមធ្យោបាយដើម្បីនឹងប្តូរចិត្តគំនិតកំពុងក្តៅក្រហាយនៃចំនួនមនុស្សយ៉ាងតិច៨០ភាគរយនេះឱ្យទៅជាចិត្តគំនិតរីករាយសប្បាយនឹងគាំទ្រអ្វីដែលសង្គមខ្មែរត្រូវការ។





ដើម្បីនឹងប្តូរចិត្តគំនិតក្តៅក្រហាយនេះឱ្យដើរទៅមុខបាន បើយើងនិយាយឱ្យខ្លីហើយស្រួលស្តាប់យើងធ្វើយ៉ាងម៉េចជួយអ្នកក្រឱ្យទៅកាន់ភាពជាអ្នកមាន។

រឿងធ្វើក្រឱ្យទៅជាមាននេះជារឿងពិបាក។ អ្នកដឹកនាំនៅគ្រប់ប្រទេសនៅសកលលោកនេះ នៅអាមេរិក ក៏ដូចនៅអឺរ៉ុប អាស៊ី ឬអាហ្វ្រិកដែរ កំពុងតែមានបញ្ហានឹងរឿងនេះ។

សូមរំលឹកថា នៅសហរដ្ឋអាមេរិកមានក្នុងពលរដ្ឋប្រមាណ៣១៣លាននាក់ មានចំនួនអ្នកក្រ

**តទៅទំព័រទី ១៤**




# ភ្នំសំពៅ បង្កប់ដោយ ជំនឿបែបប្រវត្តិសាស្ត្រ





ក្រៅពីគយគន់ទេសភាពវាលស្រែដ៏ធំល្វឹងល្វើយដាច់កន្ទុយភ្នែកនៃខេត្តបាត់ដំបងនោះ ភ្នំសំពៅក៏នៅមានល្អាងជាច្រើនធ្លាយប្រទាក់រកគ្នាពីល្អាងមួយទៅល្អាងមួយដែលភ្នំ និងល្អាងទាំងនោះបានបង្កប់នូវជំនឿរឿងព្រេងបែបប្រវត្តិសាស្ត្ររបស់ដូនតាខ្មែរកាលពីសម័យកាលដ៏យូរលង់ គឺរឿងចៅរាជកុល និងនាងរំសាយសក់ដែរ ។

រមណីយដ្ឋានភ្នំសំពៅនៅជាប់ដងផ្លូវជាតិលេខ១០អតីតផ្លូវលេខ៥៧តភ្ជាប់ពីខេត្តបាត់ដំបងទៅប៉ៃលិនមានចម្ងាយប្រមាណជា១៣គីឡូម៉ែត្រពីទីរួមខេត្តបាត់ដំបងស្ថិតនៅក្នុងភូមិភ្នំសំពៅស្រុកបាណន់ខេត្តបាត់ដំបង ។ ភ្នំនេះមានទ្រង់ទ្រាយដូចជារាងសំពៅមានកម្ពស់ប្រហែល១០០ម៉ែត្រមានផ្លូវឡើងក្រាលបេតុងអាចបើកម៉ូតូ







និង រថយន្តបានហើយផ្លូវមួយទៀត ជាជណ្តើរមានចំនួន១០៣០កាំ ។

លោក ម៉ក់ ស៊ិនណារ៉ា ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបងបានលើកឡើងថាកន្លងមកមានការភាន់ច្រឡំជាច្រើនថាប្រវត្តិភ្នំសំពៅនេះមានជាប់ពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនៃការកកើតប្រទេសជាតិកាលពីសម័យបុព្វកាលដ៏យូរលង់មកនោះ ។ លោកបញ្ជាក់ថា:ឪខ្ញុំក៏មិនដឹងថា ភ្នំសំពៅនេះមានការកកើតនៅក្នុងគ្រិស្តសករាជណាពិតប្រាកដដែរតែគ្រាន់តែដឹងតាមឯកសារក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរថាភ្នំសំពៅនេះជាប់ទាក់ទិនព្រេងនឹងនិទានខ្មែររឿងចៅរាជកុលនិងនាងរំសាយសក់ហើយរឿងនេះក៏មានជាប់ពាក់ព័ន្ធទៅនឹងការកកើតទឹកដីនៅក្នុងភូមិសាស្ត្រនេះដែរ ។

លោករៀបរាប់ថា នៅក្នុងតួភ្នំសំពៅទាំងមូលមានល្អាងចំនួន១១រួមមាន: ១- ល្អាងផ្កាស្លា ២- ល្អាងគក់ទ្រូង ៣- ល្អាងខ្យល់ ៤- ល្អាងតែងខ្លួន ៥- ល្អាងល្ខោន ៦- ល្អាងជ្រៃ ៧- ល្អាងពេជ្រ ៨-ល្អាងខ្មែង ៩- ល្អាងប្រេង ១០- ល្អាងស្ថានីយ ឬល្អាងធំ និង១១-ល្អាងក្បាលខ្មោច ។ ល្អាងទាំងនោះគឺសុទ្ធតែជាប់ពាក់ព័ន្ធនឹងកន្លែងស្នាក់នៅនិងកន្លែងតុបតែងខ្លួននាងរំសាយសក់ ។ ប៉ុន្តែលោកបានប្រាប់ថា នៅពេលបច្ចុប្បន្ននេះភ្ញៀវដែលនិយមទស្សនាតែពីរបីល្អាងទេ គឺល្អាងផ្កាស្លាល្អាងល្ខោនល្អាងស្ថានីយ ឬហៅថាល្អាងធំ ។ នៅលើកំពូលភ្នំខាងក្រោយមានវត្តមួយឈ្មោះថាវត្តគិរីរម្យកាលពីដើមឡើយគ្រាន់តែជាអាស្រមសម្រាប់សំណាក់ធមិតែប៉ុណ្ណោះ ។ នៅលើខ្នងភ្នំមានវត្តអរុណនារីឬវត្តដូនជីក្មេងនិងចេតិយធំ១ស្អាត១របស់អភិជនខ្មែរកាលពីសម័យមុន ។

ដោយឡែកនៅជុំវិញក្បែររមណីយដ្ឋានភ្នំសំពៅនោះមានចង្កោមភ្នំផ្សេងៗជាច្រើនដែលមានទំនាក់ទំនងជាមួយគ្នាតាមបែបរឿងនិទានខ្មែរចៅរាជកុល និងនាងរំសាយសក់ ។ លោកម៉ក់ ស៊ិនណារ៉ា ប្រាប់ថា: ឪមានភ្នំក្តោងភ្នំនេះពេលដែលសំពៅចៅរាជកុលដែលដឹកភ័ស្តុភារបណ្ណាការមករៀបអភិសេកជាមួយនាងរំសាយសក់ហើយត្រូវក្រពើអាធនកឿងរហូតក្រឡាប់សំពៅបាក់ក្លាយជាភ្នំក្តោង ចំណែកឯភ័ស្តុភារបណ្ណាការដែលបានបែកខ្ចាយដូចជាមាន់ទានោះក្លាយជាភ្នំទ្រុងមាន់ភ្នំទ្រុងទាហើយកន្លែងនាងរំសាយសក់ច្បូតសក់បូមទឹកនោះក៏ក្លាយជាភ្នំនាងរំសាយសក់ ។ ចំណែកក្រពើឈ្មោះអាធនពេលរីងទឹកអស់ក៏ដុះឡើងក្លាយជាភ្នំក្រពើហើយភ្នំសំពៅនេះជាប្រាសាទនាងរំសាយសក់ទើបបានជាភ្នំនេះសម្បូរល្អាងព្រោះថាល្អាងនេះយើងអាចនិយាយបានថាជាបន្ទប់រៀបចំតុបតែងខ្លួនរបស់នាងរំសាយសក់ចាំទទួលចៅរាជកុល ។

រមណីយដ្ឋានភ្នំសំពៅសព្វថ្ងៃទទួលភ្ញៀវឡើងទៅទស្សនាមិនដាច់ឡើយមានទាំងភ្ញៀវជាតិនិងអន្តរជាតិពិសេសនៅថ្ងៃបុណ្យប្រពៃណីជាតិខ្មែរនិងថ្ងៃឈប់សម្រាកចុងសប្តាហ៍ ។ លោកប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបងបានឱ្យដឹងថា: ជាមធ្យមថ្ងៃធម្មតាមានភ្ញៀវទេសចរឡើងទៅទស្សនានៅរមណីយដ្ឋានធម្មជាតិភ្នំសំពៅយ៉ាងហោចណាស់ក៏មាន៥០នាក់ដែរតែបើថ្ងៃបុណ្យឬថ្ងៃចុងសប្តាហ៍មានច្រើនដល់ទៅរយនាក់ឯណោះ ៕

តមកពីទំព័រទី ១

## អនុវិទ្យាល័យ ឆាទ័រ...

ប្រធានការិយាល័យអភិវឌ្ឍន៍សាលាបានបង្ហាញពីគុណភាពដ៏ខ្ពស់នៃសាលាដ៏ថ្មីនោះ ដោយបង្ហាញពីគំរូដែលសាលានេះធ្លាប់បានបំពេញនៅកន្លែងផ្សេងៗចំនួន១៥ប្រទេសរួចមកហើយ ។

សាលាដែលនឹងមានវិន័យច្បាស់លាស់ឱ្យសិស្សស្លៀកឯកសណ្ឋានម៉ោងរៀនក៏ច្រើន គ្រូល្អៗ នឹងទាមទារការយកចិត្តទុកដាក់ខ្លាំងពីសិស្ស និងមាតាបីតា ក្នុងន័យនេះមតិខ្លះគាំទ្រថាវត្តមានជាផលចំណេញដល់កូនចៅខ្មែរ ខ្លះទៀតមានការបារម្ភណ៏ថាសាលាអាចនឹងមិនយល់ច្បាស់ពីវប្បធម៌របស់សហគមន៍ខ្មែរដែលរស់យ៉ាងកុះករក្នុងតំបន់ ។ រ៉ូប៊ីត បានបង្ហាញបំណងពីការជ្រើសរើសបុគ្គលិកសាលាមួយចំនួនជាខ្មែរ ពីការឱ្យឪពុកម្តាយចូលរួមក្នុងចលនាសាលារៀនបង្កើតកម្មវិធីយល់ដឹងពីប្រជាជាតិសកលលោក ពីក្រុមជំនុំពិគ្រោះយោបល់សាលា ដើម្បីឱ្យដំណើរការសាលាស្រប និងវប្បធម៌ដែលគ្រួសារនៃសិស្សទទួលបាន... ។ល ។

សំនួរនឹងចំលើយជាវិជ្ជមានជាច្រើនបានផ្តោតគុណសម្បត្តិ នៃអនុវិទ្យាល័យ ឆានទ័រ ទៅនឹងការអប់រំសិស្សនៃសហគមន៍ខ្មែរ តើកូនខ្មែរអាចនឹងខ្លាចសាលាដែលតឹងតែង តែធានាលទ្ធផលនៅចុងបញ្ចប់ដែរឬទេ ?

កម្មវិធីជាបន្តទៅទៀត គឺសាលាថ្មីថ្មោងនឹងក្រុមតំណាងខ្មែរនឹងទៅជួបសហគមន៍ ដើម្បីពន្យល់នឹងឱ្យមានការចុះឈ្មោះចូលរៀននៅឆ្នាំសិក្សាក្រោយដោយចំនួនកន្លែងសិស្សក៏នៅចំហរ និងចំនួនបុគ្គលិកក៏នៅចំហរនៅឡើយដែរ ។

តែទោះជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពសេដ្ឋកិច្ចរឹតតែលំបាក ការសិក្សាដែលមានគុណភាពខ្ពស់នឹងក្លាយជាសម្បត្តិដ៏ពិប្រាកដសម្រាប់គ្រួសារ ដូចច្នេះការទាមទាររកគុណភាពសាលាលើការអប់រំ គឺជាអាទិភាពមុនអ្វីៗទាំងអស់ ៕



ហាងមាសរស្មី
SUNSHINE JEWELRY, INC.
215-271-2950
Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong
702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com




Phở Hà Saigon
7 days A Week
9am-9pm
Vietnamese Restaurant
B.Y.O.B.
ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡា-
ដែលហ្វៀចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗ
ឯទៀត ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើ
ម្ហូបនៅហាង Phở Hà Saigon
យើងខ្ញុំ ហើយធានាថា ម្ហូបអាហារហាង
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា
VISA
MasterCard
DISCOVER
320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)




Mekong River
VIETNAMESE RESTAURANT
1120-1124S Front St.,
Philadelphia, PA 19147
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ
215-467-6100
GRAND OPENING
25-5-2012
មានម្ហូបវៀតណាមគ្រប់មុខ
ហ្វើ មី គុយទាវ នំបញ្ចុក បាញ់ហយ
បាយ ម្ហូបបួស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណៈគ្រួសារ
ទទួលពិធីជប់លៀងជាលក្ខណៈគ្រួសារ ឬជួបជុំមិត្តភ័ក្រ
B
Y
O
B
Mekong River
Titan St.
Manton St.
Federal St.
Front St.
I95
Exit 20
Washington Ave.
Columbus Blvd.
មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគនិ៍យើង

តមកពីទំព័រទី ៩

# អ្នកក្រនិងអ្នកមាននៅប្រទេសខ្មែរ...

មាន៤៦លាននាក់ ឬ១៥ភាគរយ ។ និងនៅប្រទេសបារាំងក្នុងពលរដ្ឋប្រមាណ៦៥លាននាក់ មានចំនួនអ្នកក្រប្រមាណ៩លាននាក់ ឬ១៤ភាគរយ។ ហើយប្រទេសទាំងពីរនេះកំពុងខ្វល់ខ្វាយរកផ្លូវដោះស្រាយបញ្ហាភាពក្រីក្រនេះ។

នៅសហរដ្ឋអាមេរិក ដើម្បីកុំឱ្យភាពក្រីក្រក្លាយទៅជាបញ្ហាធំ ជ្រុលដោះមិនចេញរដ្ឋាភិបាលយកពីអ្នកមាន( អ្នកបង់ពន្ធដារ) ទៅជួយអ្នកក្រតាមប្រព័ន្ធមួយហៅថា "ឧបត្ថម្ភសង្គម" ឬជាភាសាអង់គ្លេស "Social Welfare"។ ប្រព័ន្ធនេះ តាមសង្កេតមើលទៅជាមធ្យោបាយដើម្បីកុំឱ្យភ្លើងឆេះព្រៃទាន់មានន័យថា បន្ថយសេចក្តីក្តៅក្រហាយក្នុងចិត្តកុំឱ្យទៅជាជ្រុលពេកហើយក៏ជាមធ្យោបាយជួយបណ្តាលឱ្យអ្នកក្រអាចរស់បាន ហើយនឹងអាចឱ្យបោះជំហានបានខ្លះទៅមុខ។

បើយើងគិតឱ្យជ្រៅមែនទែនទៅប្រព័ន្ធនេះមានលក្ខណៈជារបបសង្គមនិយមដែលធ្វើឱ្យសេដ្ឋកិច្ចរបស់ស្រុកដើរមិនលឿនទៅមុខ ។ អាមេរិកាំងកំពុងរកមធ្យោបាយដកខ្លួនចេញពីប្រព័ន្ធនេះ បើតាមខ្ញុំយល់ ។ ហើយបើតាមប្រវត្តិសាស្ត្រប្រព័ន្ធវែលហ្វែរ (Welfare) នេះកើនមានយូរណាស់មកហើយ គឺតាំងពីនៅឆ្នាំ១៨00ឯណោះម្លេះ ហើយការចាយលុយទៅលើប្រព័ន្ធនេះកាន់តែច្រើនឡើងច្រើនឡើង ។ ដូចជាសំរាប់ឆ្នាំ២០១១ក្នុងថវិការ៣៦៣០ពាន់លាន ($3.630 trillion) ដុល្លាសហរដ្ឋអាមេរិក ការចំណាយទៅលើវែលហ្វែរ(welfare)អស់៧៤៦ពាន់លានដុល្លាសហរដ្ឋអាមេរិក ហើយកំពុងឡើងទៅទៀត នេះបើយើងគិតតែពីចំណាយនៅក្នុងផ្នែករដ្ឋាភិបាលសហព័ន្ធនៃសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ព្រោះថានៅការចំណាយអំពីរដ្ឋយើងមិនគិតចូល។ ការកើនឡើងទៅលើខាងការចំណាយនេះមិនមែនគ្រាន់តែមកពីទំនិញឡើងថ្លៃតែប៉ុណ្ណោះទេ គឺមកពីចំនួនមនុស្សពឹងផ្អែកទៅលើប្រព័ន្ធនេះកាន់តែច្រើនឡើង ច្រើនឡើងផងដែរ។ ដូច្នេះមានន័យថាប្រព័ន្ធនេះនាំឱ្យមានមនុស្សកាន់តែច្រើនឡើងច្រើនឡើងមិនធ្វើការអីចាំតែយកលុយពីរដ្ឋ គឺធ្វើឱ្យមានទម្ងន់ទៅលើរដ្ឋទាញរដ្ឋមិនឱ្យរដ្ឋដើរលឿនទៅមុខបានខាងផ្នែកសេដ្ឋកិច្ច។ ហើយមិនតែប៉ុណ្ណោះប្រព័ន្ធនេះ ធ្វើឱ្យអ្នកបង់ពន្ធដារមួយភាគ ដូចជាអ្នកគាំទ្រគណបក្សសាធារណៈរដ្ឋជាពិសេសមិនសប្បាយចិត្តដែរ។ គេតែងគិតថាប្រព័ន្ធនេះមិនយុត្តិធម៌ ព្រោះថាមានអ្នកដែលមិនធ្វើអីសោះ ហើយក៏បានលុយដែរ ។

ចំពោះប្រទេសខ្មែរវិញ យើងគួរធ្វើយ៉ាងដូចម្តេចដើម្បីឱ្យប្រទេសមានការសប្បាយចម្រើនរុងរឿង ហើយឱ្យចៀសផុតពីបញ្ហាដែលអាចនឹងកើតមាននៅពេលខាងមុខ ព្រោះតែមកពីភាពមាន និងភាពក្រនេះ។

ខ្មែរត្រូវដឹងឱ្យច្បាស់ថាខ្មែរត្រូវដោះស្រាយបញ្ហាខ្មែរដោយខ្លួនឯង។ ខ្មែរទាំងអ្នកមានទាំងអ្នកក្រត្រូវតែអង្គុយទល់មុខគ្នា មើលមុខគ្នាឱ្យចំ ហើយនិយាយជាមួយគ្នា ។ ខ្មែរត្រូវចាំឱ្យច្បាស់ថា ខ្មែរសម្លាប់អស់ច្រើនហើយ ព្រោះតែមើលមុខគ្នាមិនចំ ដូចជានៅជំនាន់ខ្មែរក្រហមជាដើម ។ ខ្មែរទាំងអស់ត្រូវឈរលើគោលជំហរឱ្យច្បាស់ហើយប្តេជ្ញាចិត្តថា ត្រូវតែយល់គ្នាទៅវិញទៅមកឱ្យច្បាស់ គឺដល់ពេលធ្វើពលិកម្មសម្រេចយកគោលជំហរនេះឱ្យបាន ហើយត្រូវដឹងថាបើទាញយកគោលជំហរនេះ មិនបានទេនោះ មុខមិនអាចដោះស្រាយបញ្ហានេះបានទេ។

ទាំងអស់គ្នាដឹងថាមនុស្សឆាប់ទាស់គ្នាណាស់ សូម្បីគ្រាន់តែសំដីលើសខ្វះបន្តិចបន្តួចដើរប៉ះគ្នាដោយមិនដឹងខ្លួន ឬនិយាយមិនស្របគំនិតគ្នាក៏ទាស់គ្នាដែរ។ តទៅទំព័រទី ២២






**តមកទំព័រទី ៦** សូមសួរសាលាក្រុងឡូវែល...

បានលុះត្រាតែមានការចូលរួមសកម្មភាពពីសហគមន៍គ្រប់លំដាប់ថ្នាក់។ សហគមន៍ត្រូវសកម្មភាពចូលរួមការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង ដែលមានសមានចិត្តចំពោះសហគមន៍ និងក្រុងខ្មែរឡូវែល។ សហគមន៍ត្រូវសកម្មចូលរួមបោះឆ្នោតជ្រើសរើសអភិបាលរដ្ឋ រដ្ឋសភា និង ព្រឹទ្ធសភា ប្រចាំរដ្ឋដែលការពារ និងលើកកំពស់ផលប្រយោជន៍សហគមន៍ និងក្រុងខ្មែរឡូវែល។

សហគមន៍ត្រូវសកម្មចូលរួមបោះឆ្នោតជ្រើសរើស ប្រធានាធិបតី រដ្ឋសភា និង ព្រឹទ្ធសភាសហព័ន្ធ ដែលនឹងបង្កើតគោលនយោបាយការពារ និង លើកកំពស់ផល់ប្រយោជន៍សហគន៍ខ្មែរអាមេរិកាំង នៅក្នុងរដ្ឋម៉ាស្សាឈូសែត្ស ក៏ដូចជាទូទាំងសហរដ្ឋអាមេរិកាំងទាំងមូល។

ដោយឡែកការចូលរួមនៃសហគមន៍ក្នុងដំណើរការ និងការប្រព្រឹត្តទៅរបស់សាលាក្រុង ឡូវែល មានការពាក់ព័ន្ធដោយផ្ទាល់បំផុតនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសវាជាកត្តាកំណត់ និងសម្រេចដល់ជោគជ័យរបស់អាជីករ ពាណិជ្ជករខ្មែរអាមេរិកាំងក្នុងទីក្រុងឡូវែល។ អាជីវករអាចលើកសំណួរថា ហេតុអ្វីយើងពុំសូវមានអតិថិជន (M ainstream Customers) អាមេរិកាំងទូទៅចូលរួមមកទិញដូរនៅក្រុងខ្មែរ? និងថាតើត្រូវធ្វើយ៉ាងដូចម្តេចទើបយើងអាចទាក់ទាញអតិថិជនទាំងនោះមកទិញឥវ៉ាន់នៅហាងខ្មែរ បរិភោគអាហារនៅភោជនីយដ្ឋានខ្មែរ? មកទិញគ្រឿងអល័ង្ការនៅហាងខ្មែរ? ។ល។ យើងត្រូវសួរទៀតថា តើសាលាក្រុងបាន និងកំពុងជួយផ្សព្វផ្សាយផលិតផល និងសេវាកម្មដែលមាននៅក្នុងក្រុងខ្មែរដល់ពលរដ្ឋអាមេរិកាំងទូទៅដល់កំរិតណាហើយ? ថាតើសាលាក្រុងធ្លាប់រៀបចំឱ្យមានពិពណ៌ពាណិជ្ជកម្ម ឬកម្មវិធីវប្បធម៌ ដើម្បីបង្ហាញផលិតផល វប្បធម៌ និងសេវាកម្មនៅក្រុងខ្មែរឬទេ ។ ទាំងនេះគឺជាសំណួរដែលយើងត្រូវសួរទៅសាលាក្រុង ហើយអ្នកដែលសួរមានប្រសិទ្ធភាពជាង ណាៗទាំងអស់ គឺអាជីវករ និងពាណិជ្ជករខ្មែរ សហការជាមួយគណៈកម្មការក្រុងខ្មែរ និងសមាជិកក្រុមប្រឹក្សាក្រុងរបស់យើង គឺលោក នួន វាសនា និងចៅហ្វាយក្រុង Patrick Murphy ដែលយើងបានបោះឆ្នោតជូនកាលពីអាណត្តិកន្លងទៅនេះ។ ការចូលរួមរបស់សហគមន៍ក្នុងការធ្វើសំណូមពរទៅសាលាក្រុងនឹងជួយផ្តល់សម្ពាធនយោបាយមួយកំរិតធំទៀតដើម្បីឱ្យសមត្ថកិច្ចសាលាក្រុងពិចារណា និងសំរេចនូវសំណូមពររបស់សហគមន៍ ក៏ដូចជាសំណូមពររបស់ពាណិជ្ជករអាជីវករខ្មែរអាមេរិកាំង៕










# មេធាវីថមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិដល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

Continue From Page 04

# Cambodian Americans in Lowell...

security and public safety. Now these areas become functionally occupied and significant property tax base for the city.

In spite of the proud achievements, Cambodian community still face many old and new challenges for achieving full social and economic development potentials. One of the major challenges is shrunken customer base/market share. This challenge needs to be solved or some local businesses will face imminent bankruptcy. Any solutions to the challenge must involve at least Cambodian community, Cambodian businesses, and the City of Lowell. The community and businesses' involvement would pressure the city to prioritize the challenge of shrunken customer base in its development strategies. Community and businesses can participate in several different ways. They can attend city council meetings to share their concerns and the concerns of the community. They can sign joint petitions to the city council to make their voice heard, their concerns addressed, and their demand met.

Community and businesses can ask for enhanced security and public safety for the Cambodian business district or the Cambodia Town, public cleaning or hygiene such as timely snow removal and regular cleanup like what the city does in the Downtown Lowell; beautification of the district through, for instance, cultural landscaping; pro-growth/investment tax and zoning reforms etc. As far as security and public safety are concerned, we can demand that the city install crime watch systems to monitor criminal activities or burglary in some significant Cambodian businesses areas such as Branch Street and Cupple Square. The installation of crime watch apparatus would potentially deter burglary and other criminal activities that might otherwise take place at more frequency in the areas. The secure and safe district will lower business insurance and attract new investors into the Cambodia Town. Moreover, secure and safe Cambodia Town will reduce investment risks thus lowering price of business loans; this would incentivize more investments in the Cambodia Town and create more jobs for the Cambodian American community.

The secure and safe business district can only happen when community members and businesses owners actively participate in political processes at all levels of government. Community needs to participate in city council election to elect council members who are empathetic and compassionate to the common causes. Community needs to actively participate in electing a governor, state representatives and senators who will protect and promote the interests of the Cambodian American community and the Cambodia Town. Yet, the community needs to participate in electing president, house representatives and senators who will make policies that protect and promote the interests of the Cambodia American communities in Massachusetts and nationally.

Most importantly, the community and business participation in the process of local government is more consequential and has direct implication in their daily life; it defines to a great extent the success of local businesses and community development in general.



Local business owners may especially raise questions as to why there are not as many mainstream customers as we would like who come to purchase goods and services in the Cambodia Town; what should be done to attract the mainstream customers to the Cambodia Town, to eat cultural foods in our restaurants, to buy jewelry in our jewelry stores, to shop foods in our Asian food supermarkets etc. We can further ask if the City has done enough to help our businesses grow; if the city has aggressively promoted our authentic cultural products and services to mainstream community; if the city has ever organized local business exhibitions and cultural events to promote the local goods and services, and if the City has done enough to promote investment opportunity in the Cambodia Town.

Continue to Page 20



នាទី ប្រវត្តិសាស្ត្រ

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

(នៅពីលេខមុន)

**១៩ តុលា :** នាយទាហានខ្មែរក្រហមឈ្មោះ រិន ដែលបានវាយប្រហារលើរថភ្លើងថ្ងៃទី២៦ កក្កដា បណ្តាលឱ្យស្លាប់១៣នាក់ ចាប់ខ្លួនខ្មែរ១១នាក់ វៀតណាម៣នាក់ នឹងបរទេសស្បែកស ៣នាក់ បានធ្វើការចុះចូលខាងរដ្ឋាភិបាលជាមួយនឹងយោធា ៧៦នាក់-ក្រោយមកបានត្រូវបញ្ចូលក្នុងកងខេមរភូមិន្ទ ហើយពាក់សក្តិ៤កន្ទះ។

**២០ តុលា :** រដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម រង្ស៊ី បានត្រូវដកចេញពីមុខតំណែងជំនួសដោយលោក គៀត ឈុន លោករដ្ឋមន្ត្រីគង់ សំអុលក្រសួងកសិកម្មបានត្រូវជំនួសដោយលោក តាវ សេងហួរ ចំណែកឯរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម វ៉ា ហួត បានត្រូវជំនួសដោយលោក ចម ប្រសិទ្ធ ។ ការដកតំណែង សម រង្ស៊ី បានបណ្តាលឱ្យទ្រង់ នរោត្តម សិរីវុឌ្ឍ រដ្ឋមន្ត្រីក្រសួងការបរទេស លាលែងពីដំណែងសំដែងការមិនយល់ស្រប(២៣ តុលា) តំណែងនោះបានត្រូវជំនួសដោយ អ៊ឹង ហួត ។ ការកែប្រែរដ្ឋាភិបាលនេះ បានបង្ហាញពីការប្រេះឆានៅក្នុងរង្វង់ហ៊្វុនស៊ិនប៉ិច នឹងការពង្រឹងជំហរបស់គណបក្សប្រជាជននៅក្នុងរដ្ឋាភិបាលគណកម្មការអភិវឌ្ឍន៏កសិកម្មមួយបានត្រូវបង្កើត ហើយដាក់នៅក្រោមអធិបតីនៃលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២។

**២០ តុលា :** ជនវៀតណាម ៧នាក់បានត្រូវសម្លាប់ដោយការវាយប្រហាររបស់ខ្មែរក្រហមនៅភូមិមួយនៃខេត្តកំពង់ឆ្នាំង។

**២៤ តុលា :** ក្រឹត្យគណរដ្ឋមន្ត្រីបានលុបចោលសេចក្តីសម្រេចរបស់ សម រង្ស៊ី ដើម្បីបោសសំអាតក្រសួងគយនឹងរដ្ឋាករ។

**២៨ តុលា :** កាត់ទោសអ្នកផ្តើមធ្វើរដ្ឋប្រហារថ្ងៃ២កក្កដា ទ្រង់ចក្រពង្ស និងឧត្តមសេនីយ៍ ស៊ិន សុង ត្រូវដាក់ទោសកំបាំងមុខជាប់គុក២០ឆ្នាំ-អតីតរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ស៊ិន សេន ឱ្យជាប់គុក១៨ឆ្នាំ-ពាណិជ្ជករថៃ៩រូបត្រូវមានទោសជាប់គុកនៅក្រៅឃុំដោយលក្ខខណ្ឌ-ភ្លាមនោះក៏បណ្តេញទៅប្រទេសថៃនាពេលចប់សវនាការ។

**៣០ តុលា:** អ្នកកាសែតបារាំង"Li BERA-TION"បានត្រូវហាមមិនឱ្យចូលកម្ពុជា ។

១ វិច្ឆិកា ១៩៩៤ ហ៊ុន សែន បញ្ជាក់ថា ជនបរទេសបីនាក់ដែលខ្មែរក្រហមចាប់ខ្លួនពីថ្ងៃ២៦ កក្កដា បានត្រូវគេសម្លាប់ ដោយទម្លាក់កំហុសទៅលើបណ្តាញសារព័ត៌មាន-គេរកឃើញសាកសពបានត្រូវធ្វើកោសវិច្ឆ័យឃើញថា ជនទាំងបីបានត្រូវសម្លាប់តាមវិធីដូចគ្នា នឹងពេលដែលខ្មែរក្រយមកាន់អំណាច គឺយកស្បោងកៅស៊ូគ្របក្បាលឱ្យថប់ដង្ហើម ហើយវាយក្បាល នឹងដងចប។

**៤ វិច្ឆិកា :** រដ្ឋាភិបានបានអនុម័តច្បាប់ស្តីអីសារព័ត៌មានដែលមានលក្ខណៈតឹងតែងយ៉ាងខ្លាំង -ច្បាប់នោះបានទទួលការតវ៉ាពីអ្នកកាសែត នឹងអង្គការមនុស្សធម៌នៅកម្ពុជា ក៏ដូចជានៅអន្តរជាតិ ។

**១៦វិច្ឆិកា ១៩៩៤ :** បង្កើតអាជ្ញាធរជាតិខាងកិច្ចការព្រំដែន

**២២វិច្ឆិកា :** កម្មករថៃ៣៣នាក់ បានត្រូវចាប់ខ្លួនដោយក្រុមប្រដាប់អាវុធដែលគេសំគាល់ថា ជាក្រុមខ្មែរក្រហម, ២២នាក់ត្រូវគេសម្លាប់ចោល -កម្មករទាំងនោះធ្វើការឱ្យក្រុមហ៊ុនកាប់ឈើថៃ

**២៨វិច្ឆិកា :** ប្រទេសអូស្ត្រាលីប្រកាសបង្កើតទំហំជំនួយយោធាពីរដងលើសមុន ជំនួយនោះឥតមានរាប់បញ្ចូលសព្វាវុធ និងគ្រាប់រំសេវទេ

**៧ធ្នូ ១៩៩៤ :** អ្នកទេសាទវៀតណាម២រូបបានត្រូវគេសម្លាប់ ហើយ២នាក់ទៀត រងរបួសនៅព្រែកកំពិស (ខេត្តកណ្តាល)

**៨ធ្នូ :** អ្នកសារព័ត៌មានឈ្មោះ ចាន់ តារា បានត្រូវគេសម្លាប់នៅកំពង់ចាម -អ្នកកាសែតនោះបានសរសេរពាក់ព័ន្ធនឹងករណីពុករលួយលោក ហ៊ុន ណេង **តទៅលេខក្រោយ**




# សុខភាពល្អប្រសើរក្នុងដៃលោកអ្នក

បើលោកអ្នកមានជំងឺ ឈឺហើមជើងដៃពិបាកធ្វើចលនា -ឈឺនោមច្រើន -ដេកស្រមុកខ្លាំង -មានស្ករច្រើនក្នុងឈាម -ឡើងទម្ងន់ធាត់ -ស្បែកឡើងកន្ទួល លោកអ្នកត្រូវចាំថា មានឱសថសក្តិសិទ្ធមានលក្ខណៈជាប្រភេទចំណី អាចជួយឱ្យសះស្បើយបានយ៉ាងឆាប់រហ័ស ។ ឱសថធម្មជាតិ ជាប្រេងចម្រាញ់ចេញពីពន្លកគ្រាប់ស្រូវមានការត្រួតពិនិត្យដោយវេជ្ជបណ្ឌិតត្រឹមត្រូវ អាចប្រើដោយមិនប្រឆាំងនឹងថ្នាំពេទ្យ ដែលប្រើប្រាស់រាល់ថ្ងៃទេ ។

លោក វិចិត្រ ភូស៊ីវុឌ ៦២ឆ្នាំ មុនប្រើ"អេមស្តា" គាត់ឈឺទឹក នោមផ្អែម ឈឺបេះដូង លើសឈាម -"អាលើជី"-ឈឺសន្លាក់ ដៃជើង ឈឺក្រពះ...។ល។

**បន្ទាប់ពីបានប្រើ"អេមស្តា"**

លេប៩គ្រាប់ក្នុង១ថ្ងៃ-បីថ្ងៃក្រោយមក អន់ឈឺសន្លាក់ដៃជើង -១ខែក្រោយអាចរត់ឡើងជណ្តើរបាន-បីខែក្រោយទៀតសរសៃឈាម២លែងស្ទះ-ឥឡូវនេះអាចរត់បាន១០គីឡូម៉ែត្រ-ធ្វើតេស្តឈាមមានភាពហ្មឹងទំល្អឡើងវិញ៕





**ចង់ដឹងបន្ថែមលេខទូរស័ព្ទលេខ**
-ហ្វីឡាខាងត្បូង ២១៥ ២៣៧ ៥៧០៥ សាមន់ថា
-ហ្វីឡាខាងជើង ២១៥ ៦៦៧ ៨៤៣១ រ៉ដែរ





# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



# ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**



# ខ្មែរជួសជុលរថយន្ត
# KHMER AUTO REPAIR

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ជារដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្បូង
- មើលតម្រងទ្រនាប់ និងពីញង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ
# រ.ជ.រ.ប.ខ លោកតា សឺន សាន



ដោយ : ម៉ម យឺន

(តពីលេខមុន)



ជួយបង្ហាត់បង្រៀនជាពិសេសជួយថវិកាសម្រាប់ចំណាយគ្រប់មុខទាំងបុគ្គលិក ទាំងសម្ភារៈព្រមទាំងបង្កើតរោងពុម្ភយ៉ាងទាន់សម័យសម្រាប់បោះពុម្ភប្រតិបត្តិព័តិមាន ខិតប័ណ្ណ និងឯកសារផ្សេងៗសម្រាប់ផ្សព្វផ្សាយ ។

មានកិច្ចការច្រើនណាស់ ដែលរណសិរ្សជាតិ និងកងកម្លាំងទ័ព កជរបខ បានបំពេញនៅក្នុងផលប្រយោជន៍ប្រទេស និងជនជាតិខ្មែរ នៅក្នុងពេលធ្វើការតស៊ូនោះ នៅក្នុងគ្រប់វិស័យសំខាន់ៗទាំងអស់ ។ ដូច្នេះហើយទោះបីកងទ័ពយួនក្រហមរួមជាមួយកងទ័ពខ្មែរ យួន មានផែនការចង់កំទេចបំផ្លិចបំផ្លាញយ៉ាងណាក៏ដោយ ក៏ពុំអាចសម្រេចទៅបានដែរ ។

ផ្ទុយទៅវិញ ចាប់តាំងពីឆ្នាំ១៩៨៥ កងកម្លាំងទ័ព កជរបខ បានបើកការវាយប្រហារយ៉ាងពេញមុខ ក្រោយពីបានអនុវត្តយុទ្ធសាស្ត្រថ្មីជ្រៀតចូលទៅក្នុងផ្ទៃប្រទេសទាំងមូលមក ។ ពីព្រោះនៅក្នុងប្រទេសប្រជាពលរដ្ឋគ្រប់ភូមិ ស្រុក និងក្រុង បានគាំទ្រយ៉ាងពេញទំហឹងអស់ទៅហើយ ធ្វើឱ្យមេទ័ពសំខាន់ៗរបស់ កជរបខ បានបញ្ជាទ័ពទាំងកងៗដោយផ្ទាល់ទៅវាយប្រយុទ្ធវាយឆ្មក់ វាយរំខានដាក់អន្ទាក់ ពួនស្ទាក់ កងទ័ពយួន និងខ្មែរយួនទាំងយប់ទាំងថ្ងៃជារៀងរហូត ។

## ភាគ១៦-ដំណោះស្រាយបញ្ចប់សង្គ្រាមឆ្នាំ ១៩៩១

ដោយសារតែការបង្កើត និងបន្តធ្វើកិច្ចប្រតិបត្តិការណ៍សឹកវាយប្រយុទ្ធកាន់តែខ្លាំងឡើងៗ នៃកងកម្លាំងទ័ព កជរបខ និងមានភាគីនៃរណសិរ្ស ហ៊្វុនស៊ិនប៉ិច រាជានិយមចូលរួមផង ទើបបណ្តាលឱ្យមេដឹកនាំខ្មែរ ក្រោមខ្សែញាក់របស់កងទ័ពយួនក្រហម ត្រូវតែយល់ព្រមចរចាបញ្ចប់សង្គ្រាម ។ ដើម្បីបង្រួបបង្រួមជនជាតិខ្មែរ គ្រប់និន្នាការនយោបាយឱ្យចូលមកសាមគ្គីគ្នាស្ថាបនាកសាង និងការពារប្រទេស និងប្រជាជាតិខ្មែរ ឱ្យបានសន្តិភាព ឯករាជ្យ និងរីកចំរើនលូតលាស់ឡើងវិញ ។

មូលហេតុដែលបណ្តាលឱ្យ មេដឹកនាំខ្មែរក្រោមខ្សែញាក់យួននេះ យល់ព្រមបញ្ចប់សង្គ្រាម គឺដោយសារប្រទេសសង្គមនិយមវៀតណាមយួន ពុំមានលទ្ធភាពនឹងជួយគាំទ្រសង្គ្រាមនៅក្នុងប្រទេសខ្មែរ ដែលកងទ័ពយួនក្រហមបានចូលមកវាយលុកលុយកាលពីក្នុងឆ្នាំ១៩៧៨បន្តទៅទៀតទេ ។

ពីព្រោះប្រទេសសហភាពសង្គមនិយមសូវៀត មានកើតវិបត្តិនយោបាយធ្ងន់ធ្ងរ ផ្ទៃក្នុងប្រទេសរបស់ខ្លួន ។ សូវៀតបានប្រាប់មកមេដឹកនាំយួនវៀតណាមថា បើចង់បន្តសង្គ្រាមជួយកងទ័ពខ្មែរយួនទៅមុខទៀត យួនវៀតណាមត្រូវតែមានលុយសម្រាប់ចំណាយខ្លួនឯងចុះ ។ ចំណុចត្រង់នេះហើយ ដែលមេដឹកនាំវៀតណាមត្រូវយល់ព្រមដកកងទ័ពខ្លួនចំនួន២សែននាក់ ចេញពីប្រទេសកម្ពុជាទៅវិញ នៅឆ្នាំ១៩៨៩ ហើយបញ្ជាឱ្យមេដឹកនាំខ្មែរ មានខ្សែញាក់យួននេះ យល់ព្រមចរចាបញ្ចប់សង្គ្រាមនេះទៅ ។

ម្យ៉ាងទៀតកងទ័ពយួន និងកងទ័ពខ្មែរ-យួន បានដឹងច្បាស់ថា កងកម្លាំងទ័ពរំដោះជាតិនៃរណសិរ្សជាតិ មិនមែនកុម្មុយនិស្ត២ កំពុងតែប្រយុទ្ធវាយប្រហារសម្រុក ពាសពេញប្រទេសកាន់តែខ្លាំងឡើងៗផង ។ ព្រមទាំងកងទ័ពខ្មែរយួន កំពុងធ្លាក់ទឹកចិត្ត បោះបង់ចោលការប្រយុទ្ធ ស្ទើរគ្រប់សមរភូមិ ។ មានមួយចំនួនធំបានរត់ចោលជួរ និងរត់ទៅចូលរួមអាវុធជាមួយរណសិរ្សរំដោះជាតិវិញ ។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាថ្ងៃបញ្ចប់សង្គ្រាមក្នុងប្រទេសកម្ពុជា ដែលជាថ្ងៃចុងក្រោយនៃកិច្ចប្រជុំចរចាគ្នា រវាងភាគីទាំង៤ គឺភាគីរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ភាគីហ៊្វុនស៊ិនប៉ិច ភាគីខ្មែរក្រហមកម្ពុជាប្រជាធិបតេយ្យ និងភាគីខ្មែរ ក្រហមកម្ពុជាប្រជាមានិត ធ្វើនៅក្រុងប៉ារីស ប្រទេសបារាំងក្រោមអធិបតីភាពនៃសហប្រធានមកពីប្រទេសបារាំង និងប្រទេសឥណ្ឌូណេស៊ី និងក្រោមការជួយឧបត្ថម្ភជ្រោមជ្រែងពីអង្គការសហប្រជាជាតិ ដែលមានប្រទេសចំនួន១៨ចូលរួមជាតំណាង និងចុះហត្ថលេខាទុកជាភស្តុតាងផងដែរ ។

សន្និសីទអន្តរជាតិនេះ បានចេញសេចក្តីសម្រេចឱ្យមានសន្ធិសញ្ញាអន្តរជាតិបញ្ចប់សង្គ្រាមក្នុងកម្ពុជាពេលនោះ ។ មានអត្ថន័យ និងអត្ថប្រយោជន៍ធំធេងខ្លាំងណាស់ សម្រាប់ប្រទេស និងប្រជាជាតិខ្មែរ ដែលជាប្រទេសមួយនៅភូមិភាគអាស៊ីអាគ្នេយ៍ (មានតលេខក្រោយ)


ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ
CONWAY INSURANCE



For over 23 years, Conway Insurance Agency has been your community's one-stop provider of quality insurance services in New England.
We are a full-service agency offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត
មុខរបរ និងសុខភាព
យើងនិយាយភាសាខ្មែរ

CONWAY INSURANCE AGENCY
P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480
www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com



East Coast Center
for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement
Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៏កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
(617) 464 - 0001

Continue From Page 17

## Cambodian Americans...

These are the questions that need to be raised to the city government; and those who can ask the questions more effectively are Cambodian American businesses; they need to work closely with the Cambodia Town Committee, Councilor Vesna Nuon and Mayor Patrick Murphy whom they voted for in the last city council election. Community members' involvement would put more weight in making sure that our concerns are effectively heard and that the City government acts effectively on their collective demands.


## DELI BUSINESS FOR SALE

(លក់ដោយម្ចាស់ហាង)

លក់ហាងកាហ្វេ,ដូណាត់,ធ្វើនំដុត,ស្ថិតនៅក្បែរសលកវិទ្យាល័យ Temple University (ជ្រុងមហាវិថី Broad និង Girad )មានមនុស្សធ្វើដំណើរច្រើន ហាងមានលំនឹងល្អជាង១០ឆ្នាំហើយ ម្ចាស់ហាងចូលនិវត្តន៏ ហើយត្រូវការលក់ជាប្រញាប់ ។

ទូរស័ព្ទ **(215) 763 8300** ឬ **(215) 906 2867** សម្រាប់បង្ហាញកន្លែង

## ត្រូវការលក់ហាងធ្វើក្រចក

នៅតំបន់ "Providence Plaza Mall"

មានកៅអី៦មានតុធ្វើក្រចក៨ មានបន្ទប់ខ្ញុំដករោម

មានម៉ាស៊ីនបោកហាល បើចង់ទិញពិតប្រាកដ

សូមទូរស័ព្ទ(៦១៧)៥១៥ ៥៣១១

តម្លៃអាចតថ្លៃបាន




Agent: Roeut Chak

# PK Property, Inc.

## ក្រុមហ៊ុនអចលនវត្ថុ លក់ ដូល គ្រប់ប្រភេទ

ភីខេ ប្រភីធី (215) 635-5100
Roeut Chak - (267)872-3516
409 West Cheltenham Avenue
Melrose Park, PA 19027

**សម្រាប់បើកភោជនីយដ្ឋានខ្មែរ**

- 5706 N. 5th Street, Philadelphia PA 19120

ពីដើមជាភោជនីយដ្ឋាន ឥឡូវបិទ២០០០sqft បន្ទប់ដេកបី ជាន់ទី២ជា Apt គ្រឿងបរិក្ខាទាំងអស់នៅក្នុងផ្ទះឈ្នួល២០០០/ខែ

5734 N.2nd Street, Philadelphia, PA 19120
២៥០០ sqftពីដើមជាភោជនីយដ្ឋាន មានកន្លែងចតឡាន៧៥- ឈ្នួល ២១០០/ខែ

**កន្លែងភ្នាក់បៀរ BEER DELI**

- $16000/wk, Phila, Asking $99,000w/ Real Estate
- $13000wk, Phila., Asking $79,000w/ Real Estate
- $9000/wk, Asking $320.000
- $13,500/wk Asking $42000

**កន្លែងបោកគក់ដាក់កាត Co. Laundry**

- 100 Machines, 4500 sqft Asking $170,000
- $4500/wk Asking $200000
- 500/wk Bucks County; Asking $350,000

**កន្លែងចែកចាយបៀរ** Beer Distributor

- $1.3 Mil/yr, Bucks County, $250000 yearly income, Asking $1,150,000
- $75000/yr Philadelphia Asking $790,000 with RE
- 11,000,000 Philadelphia Asking $430,000

**សាឡុងធ្វើក្រចក Nail Salon**

- $18000/wk, Montgomery County, Asking $380,000
- $15000/wk South Jersey Asking $370,000

**សូមចូលទៅវេបសាយ**

www.pkpropertyinc.com to check more listings and office information.




# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហាង



**ជោគជតាប្រចាំសប្តាហ៍**

**ឆ្នាំជូត**

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមក ហើយនោះក្នុងរយ:ពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

**ឆ្នាំថោះ**

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយ:ពេលនេះ សុទ្ធតែផ្តល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវករ រកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

**ឆ្នាំមមី**

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយ:ពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

**ឆ្នាំរកា**

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិត១ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕

**ឆ្នាំឆ្លូវ**

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

**ឆ្នាំរោង**

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

**ឆ្នាំមមែ**

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះ១នាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់បើ អាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

**ឆ្នាំច**

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

**ឆ្នាំខាល**

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

**ឆ្នាំម្សាញ់**

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

**ឆ្នាំវក**

ក្នុងរយ:ពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់១ចង់ចាញ់ឈ្នះគ្នានោះឯង ៕

**ឆ្នាំកុរ**

នៅក្នុងរយ:ពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

# វិធីបន្ធូរនិងលំហែកាយនិងចិត្ត និងព្រៃបជញ្ជក់រស់ជាតិជីវិត

# Method how to relax mind and body in order to enjoy life.



**តពីលេខមុន**

ចូលអនុវត្តពីតូចទៅធំ ពីតិចទៅច្រើន បន្តិចម្តងៗទៀងទាត់ ទំលាប់ថ្មីនឹងចាប់ផ្តើមដុះដាលរីកលូតលាស់ក្នុងប្រពន្ធរូបកាយនិងចិត្តអ្នក អ្នកកាន់តែទទួលភាពស្រណុកសុខសប្បាយក្នុងជីវិតច្រើនឡើងៗ។ ចូរអនុវត្ត អនុវត្ត អនុវត្ត ។

បើអ្នកបានយល់ដឹង និងចេះស្ទាត់ហើយ សូមជួយបន្តចំណេះនេះទៅគ្រួសារផ្ទាល់មិត្រភ័ក្តិមនុស្សនានា ដើម្បីជាផលប្រយោជន៍លើកកំពស់គុណភាពជីវិតឱ្យធំទូលាយឡើងៗ ពីគ្រួសារតូចទៅសង្គមប្រទេស និងសាកលលោកទាំងមូល ។

បើអ្នកចង់ដឹងលំអិតបន្ថែមអំពីបច្ចេកទេសការតម្រង់សតិបើកទូលាយនេះ សូមរកទស្សនាបទសម្ភាសន៍និងអត្ថបទនានារបស់លោក ហ្វ្លរ៉ង់ ក្នុងគេហទំព័រ Conscious TV or You tube or http://www.tathagata.document - Mr. Florian Schlosser ។

សូមអ្នកអានទាំងអស់ទទួលនូវសុខសន្តិភាពពិតប្រាកដ។ សូមអ្នកអានទាំងអស់ទទួលនូវសុភមង្គលពិតប្រាកដតរៀងទៅ។

សូមឱ្យកុសលទាំងឡាយដែលកើតឡើងអំពីការសសេរការស្វែងយល់ និងការយល់ដឹងសច្ចៈធម៌ដ៏ឧត្តុង្គឧត្តមនេះ នាំឱ្យពន្លឺព្រះពុទ្ធសាសនាសាយភាយគ្រប់ទិសទីជាសុភមង្គលដល់មនុស្សជាតិលើភពផែនដីទាំងមូល។ អត្ថបទចប់ដោយបរិបូរណ៍។

ខ្ញុំ **ម៉ៅ ច័ន្ទសំណុំ** សូមអរគុណចំពោះការគាំទ្រ និងយកចិត្តទុកដាក់អានអត្ថបទដ៏វែងនេះសូមជំរាបលា។

**<u>កំណត់និពន្ធ</u>**

ស្នាដៃសរសេររបស់លោក ម៉ៅ ច័ន្ទសំណុំ បានផ្សាយចប់សព្វគ្រប់ ។ ខ្មែរផុសស.រ.អា សូមសម្តែងអំណរគុណដល់អ្នកនិពន្ធក្នុងនាមនៃអ្នកអានទាំងអស់ សូមឱ្យលោក និងគ្រួសារជួបនឹងសេចក្តីសុខចំរើន ពីភាពជ្រះថ្លាក្នុងការប្រើពេល និងឧបត្ថម្ភគតិថ្លៃថ្លា បំរើចំពោះសហគមន៍ខ្មែរ ៕






# ខណៈពេលមួយដ៏សែនសុខនឹងមនោរម្យ



**ដោយ : គឹម ភៀន**

●●●ធ្វើម្តេចឱ្យខ្ញុំអាចបំភ្លេចពេលមួយដ៏សែនមនោរម្យនោះបាន? ទេមិនអាចបានទេ!ខ្ញុំនឹងឱបក្រសោបនូវអនុស្សាវរីយ៍ដ៏សែនសុខនឹងខ្ពង់ខ្ពស់ទាំងអស់នោះទៅតាមខ្លួនរហូតដល់ក្នុងផ្នូររបស់ខ្ញុំ ។ ប្រសិនបើមនុស្សទាំងឡាយគិតថា ទ្រព្យសម្បត្តិ និងកិត្តិយសខ្ពង់ខ្ពស់នៅក្នុងសង្គមដែលគ្មានអ្វីជាទៀងទាត់នេះជាសុភមង្គលតែមួយគត់របស់គេផ្ទុយទៅវិញ ខ្ញុំជ្រើសរើសយកអំពើដ៏ខ្ពង់ខ្ពស់និងមាគារដ៏ប្រសើរសម្រាប់បំពេញនូវគោលបំណងដ៏ថ្លៃថ្លារបស់ខ្លួនថា ជាក្តីសប្បាយនឹងសុភមង្គលក្នុងជីវិតដ៏ខ្លីនៅក្នុងលោកនេះ ។

មានអ្នកណាម្នាក់ដែលមិនដែលស្នេហានឹងដែលមិនបានទទួលក្តីស្នេហាតបមកវិញ? មែនហើយ! ខ្ញុំជឿថា មនុស្សម្នាក់ៗសុទ្ធតែធ្លាប់បានស្គាល់នឹងធ្លាប់មានឱកាសមួយនោះ គឺឱកាសកំពុងស្រឡាញ់នឹងបានស្រឡាញ់តបវិញក្នុងជីវិតរបស់គេ ប៉ុន្តែមនុស្សម្នាក់ៗមិនសុទ្ធតែបានសេចក្តីសុខនោះទេ ព្រោះក្តីស្នេហាទាំងនោះ មិនសុទ្ធតែបានហូរចេញមកពីបេះដូងដ៏ឧត្តមនឹងគ្មានហ៊ានលះបង់ជូនចំពោះមនុស្សដែលខ្លួនស្រឡាញ់នូវអ្វីដ៏តិចតួចមួយក៏សឹងតែមិនបានផង។ ជាក្តីស្នេហាដែលបានចញ្ចឹមបំប៉នដោយសម្លឹងឃើញតែផលប្រយោជន៍រៀងៗខ្លួន ឬក៏មកពីមនុស្សម្នាក់ក្នុងចំណោមគូស្នេហ៍ទាំងពីរនោះមានចិត្តសម្លឹងរកតែប្រយោជន៍ផ្ទាល់ខ្លួន ។

យើងទាំងពីរប្រាណបានស្គាល់គ្នានៅមុនរដូវវ៉ាកងតូចនាឆ្នាំមួយនោះ,យូរណាស់ហើយ ។ ឆ្នាំនោះ គឺឆ្នាំសិក្សា១៩៦៥នៅក្រោមដំបូលវិទ្យាល័យ នាពេលវិថីទាំងឡាយនៃទីក្រុងភ្នំពេញ,រាជាណាចក្រកម្ពុជាក្រហមឆ្អៅដោយផ្កាកោករីករោយ... យើងបានស្រឡាញ់គ្នាហើយកំពុងតែបានស្រឡាញ់តែក្នុងចិត្តរៀងៗខ្លួន ។ ក្តីស្នេហ៍បានសន្សឹមៗនឹងស្ងាត់ស្ងៀមតែពោពេញដោយថាមពលខ្លាំងឡើងៗតាមពេលវេលា...ចូលមកស្ថិតក្នុងព្រលឹងយើងទាំងពីរ ។ គ្មានអ្នកណាម្នាក់ហ៊ានសារភាពនូវអ្វីដែលកំពុងកើតឡើងនៅក្នុងបេះដូងរបស់ខ្លួនឡើយ ។ យើងមានតែក្តីញញឹមលាក់នៅក្តីព្រួយបារម្ភពេលយើងជួបគ្នាម្តងៗ ។ ខ្ញុំចង់សារភាពនូវរឿងស្នេហ៍ដ៏ធំធេងនេះចំពោះ"គេ"តែមាត់ខ្ញុំត្រូវបិទជិតហារមិនរួចសោះ ។ ដោយសារតែភាពញាប់ញ័ររន្ធត់នៃបេះដូងខ្ញុំបាត់អស់ឱកាសយ៉ាងច្រើន ដើម្បនិយាយនូវពាក្យថា "បងស្រឡាញ់អូន" ។ ឯ"គេ" "វិញក៏ដូចច្នោះដែរ..."គេ" រង់ចាំអស់ពេលដ៏ច្រើន ដើម្បីបានបង្ហាញខ្ញុំនូវកែវភ្នែកដ៏ភ្លឺថ្លាខៀវស្រងាត់របស់ "គេ" ហើយសារភាពដោយកាត់ក្តីអៀនខ្មាស់របស់ខ្លួននឹងខ្សឹបប្រាប់ថា "អូនក៏ស្រឡាញ់បងណាស់ដែរ" ប៉ុន្តែ... អត់ទេ! យើងមិនទាន់ដើរទៅដល់ចំណុចនោះទេ ។ វាហាក់ដូចជានៅឆ្ងាយពេកណាស់ពីរង្វង់ដៃយើងទាំងពីរ ។

មុនពេលវ៉ាកងតូចថ្នាក់យើងមានពិធីជប់លៀងមួយខ្ញុំបានប្រមូលអស់ក្តីក្លាហានពីខ្លួនប្រគល់សំបុត្រមួយច្បាប់ជូន "គេ"ដោយនិយាយថា: "ខ្ញុំសង្ឃឹមថាវ៉ាកងនេះមិត្តនឹងបានរីករាយចូលឆ្នាំថ្មីជាមួយគ្រួសារនៅឯស្រុកកំណើតចំណែកខ្ញុំវិញនឹងនៅទីនេះរង់ចាំមិត្តត្រឡប់មកវិញដើម្បីបន្តការសិក្សាជាមួយគ្នាក្នុងថ្នាក់ដ៏សប្បាយរីករាយរបស់យើង" ។ "គេ"គ្មានឆ្លើយតបមួយម៉ាត់ណាសោះ,ខ្មាស់អៀនពេកក៏កាន់យកសំបុត្រដាក់ចូលក្នុងសំពាតរួចដើរតម្រង់ទៅកាន់មិត្តភ័ក្តិរបស់ "គេ"ក្នុងពិធីជប់លៀងទៅ! ។

ក្រោយពិធីជប់លៀងយើងបានសន្យាថានឹងមកជួបជុំគ្នាពីរថ្ងៃទៀតដើម្បីសិក្សារួមគ្នា ព្រោះចុងឆ្នាំៗនោះយើងត្រូវប្រឡងយកមធ្យមសិក្សាប័ត្រភាគទី២ ។ "គេ"មិនបានមករៀនទេ! ហេតុអ្វីទៅន៎? ឱព្រះអើយ! ប្រហែល "គេ" ខឹងនឹងខ្ញុំទេដឹងដោយហ៊ានសរសេរខ្សឹបប្រាប់ "គេ"យ៉ាងគឃ្លើនថា ស្រឡាញ់គេនោះអី! ប្រសិនបើខ្ញុំកុំសរសេរសំបុត្រឱ្យ"គេ" វាមិនប្រសើរជាងទៅហើយ? សមម្លេះខ្ញុំមិនបាច់ចាំព្រួយបារម្ភនឹងស្ថិតនៅក្នុងភាពរងទុក្ខយ៉ាងនេះទេ ។

ដល់ថ្ងៃទីពីរនៃថ្នាក់សិក្សារួមមានមិត្តជិតស្និទ្ធរបស់ "គេ" ម្នាក់កាន់សុំត្រមួយច្បាប់តម្រង់មករកខ្ញុំហើយប្រកាសដោយពាក្យផ្អែផ្អាថា: ធិតាគេមានមិត្តច្រើនណាស់ តែគេ "ជ្រើសរើស" យកមិត្តឯងដើម្បីសរសេរសំបុត្រផ្ញើឱ្យគេ ប្រសិនបើមានការអីប្រែប្រួលនៅទីនេះ ព្រោះគេបានទៅជួបជុំគ្រួសារគេនៅឯស្រុកកំណើតឯណោះ" ។ ដើម្បីលាក់នូវការអៀនខ្មាស់ខ្ញុំខំធ្វើ ឬក៏ក្លាហានទទួលយកសំបុត្រដោយឆ្លើយឡើង:"បាទខ្ញុំទទួលបញ្ជាលោកស្រី! " ។ តាំងពីពេលនោះមកក្តីស្នេហ៍របស់យើងបានរីកចំរើនយ៉ាងរហ័សហើយបានពង្រឹងថាមពលយើងទាំងពីរនាំឱ្យយើងខំធ្វើការសិកស្សាទ្វេជាពីរជាបីដង ហើយក៏បានប្រឡងចេញទាំងអស់គ្នាដោយជោគជ័យ ។ សង្សាខ្ញុំបានជ្រើសរើសយកមហាវិទ្យាល័យគរុកោសល្យហើយបានខំធ្វើការមួយឆ្នាំយ៉ាងហត់នឿយក៏បានចេញទៅធ្វើជាសាស្ត្រាចារ្យនៅទីរួមខេត្តកំណើតរបស់ខ្លួនទៅ ឯខ្ញុំម្នាក់ឯងត្រមឹងត្រមោចរស់នៅក្នុងសយនដ្ឋាននៃសាកលវិទ្យាល័យនៃមហាវិទ្យាល័យកសិកម្មយ៉ាងកណ្តោចកណ្តែង ។

បែកឆ្ងាយពីគ្នាយ៉ាងយូរតែយើងអាចទទួលបានសំបុត្រតែមួយ ឬពីរប៉ុណ្ណោះក្នុងមួយខែៗ នៅមានត) ។

តមកពីទំព័រទី ១៤

## អ្នកក្រនិងអ្នកមាននៅប្រទេសខ្មែរ...

ចំពោះអ្នកក្រនិងអ្នកមានវិញ គ្រាន់តែភាពមានក្រនេះវាធ្វើឱ្យមនុស្សនិងមនុស្សទាស់គ្នាទៅហើយ មិនបាច់ចាំមានអាការណ៍អ្វីផ្សេងទៀតទេ ។ ដូច្នេះគោលជំហរដែលប្រកាន់យកឱ្យបាននោះគឺភាពនឹងនរមិនខឹងច្រឡោតខំប្រឹងតាមស្តាប់ឱ្យយល់គំនិតគ្នាទៅវិញទៅមក ។ ប្តីប្រពន្ធទាស់គ្នាភាគច្រើនដោយមកពីមិនយល់គ្នាទៅវិញទៅមក ។ ពិភពលោកមានសង្គ្រាមមួយភាគធំដោយមកពីមិនយល់គ្នា។ ដូច្នេះកាលណាយល់គ្នាគេអាចដោះស្រាយអ្វីមួយបាន ឬគេអាចថា បានដោះស្រាយបានទាល់តែយល់គ្នា ។ យើងក៏យល់ដែរថា និយាយវាស្រួលទេ តែធ្វើវាពិបាក។ ហើយដើម្បីពុះពារការពិបាកនេះបានត្រូវការការខំ ។ ហើយយើងក៏យល់ដែរថា ការខំនេះហើយដែលមនុស្សភាគច្រើនចៀសវាង។

ចំពោះភាពនឹងនរមិនខឹងច្រឡោតខំប្រឹងតាមស្តាប់ឱ្យយល់គំនិតគ្នាទៅវិញទៅមកវិញនេះតើធ្វើយ៉ាងម៉េចទើបសម្រេចបាន? នេះជាលក្ខណៈសំខាន់មួយដែលចែកមនុស្សម្នាក់ពីមនុស្សម្នាក់ទៀតឱ្យឃើញខុសគ្នាចំពោះឥរិយាបថកិរិយាមារយាទឬកពា។ ដើម្បីនឹងសម្រេចភាពនេះបានយ៉ាងតិចគេត្រូវការជាចាំបាច់ គឺគិតធ្វើ និងកាន់វិន័យឱ្យបានជាប់។

គិតធ្វើ និងកាន់វិន័យជារឿងពិបាក ព្រោះទាំងបីនេះវាទាក់ទងនឹងចិត្ត។ ហើយយើងទាំងអស់ដឹងថាចិត្តមិននឹងនរទេ ជួនកាលរេទៅឆ្វេង ឬទៅស្តាំយោលទៅតាមកំហឹងឆាបឈ្មួលមួលកន្ត្រាក់ផ្ទុះចេញពីការប្រែប្រួលក្នុងខ្លួនយើង ។ បើតាមវិជ្ជាសាស្ត្រការប្រែប្រួលបណ្តាលមកពីការប្រទាញប្រតោងគ្នានៃជីវៈគីមី(biochemical reaction) ដែលបណ្តាលមកពីការប្រែប្រួលផ្លាស់ប្តូរនៃស្ថាការណ៍ក្នុងខ្លួនយើង



ឬពីក្រៅខ្លួនយើង។ យើងទាំងអស់ខ្ញុំយល់ថា សុទ្ធតែធ្លាប់បានពិសោធនឹងចិត្តប្រែប្រួលនេះ ឧទាហរណ៍ជួនកាលយើងស្រាប់តែព្រួយឬស្រាប់តែខឹងដោយរកមូលហេតុមិនឃើញ។ តាមពិតវាមានមូលហេតុគឺជួនកាលធាតុអាកាសផ្លាស់ប្តូរនៅជុំវិញខ្លួនយើងតែយើងមិនដឹង ឬមិនបានគិត ។ ធាតុអាកាសនេះហើយដែលធ្វើឱ្យមានការផ្លាស់ប្តូរក្នុងខ្លួនយើង។

ដូច្នេះតើយើងអាចទប់ចិត្តឬដឹកនាំចិត្តយើងបានទេ? អ្នកកាន់សាសនាព្រះពុទ្ធគួរតែចេះទប់ចិត្តឬដឹកនាំចិត្តបានដោយស្រួល ។ ព្រោះថាក្នុងធមិព្រះពុទ្ធមានការបង្រៀនឱ្យចេះទប់ចិត្តដឹកនាំចិត្ត ។ ម្យ៉ាងទៀត យើងគួរសង្កេតមើលតួឯកកុនគេចេះសើចយំចេញទឹកភ្នែកជាដើម ។ សើចយំចេញទឹកភ្នែកនេះ គឺមកពីចិត្ត។ ដូច្នេះតើគេធ្វើយ៉ាងម៉េចទើបគេអាចពត់ចិត្តគេបាន។

ខ្ញុំយល់ថាមនុស្សចង់ជួយគ្នាទៅវិញទៅមក។ ហើយខ្ញុំយល់ទៀតថា មនុស្សមិនជួយគ្នាទៅវិញទៅមកនោះមូលហេតុគឺមកពីមិនយល់គ្នា។ ដូច្នេះអ្នកមាន និងអ្នកក្រនឹងជួយគ្នាទៅវិញទៅមកនៅពេលណាគេយល់គ្នាទៅវិញទៅមក។

ដើម្បីនឹងមនុស្ស និងមនុស្សដោះស្រាយបញ្ហារវាងគ្នា និងគ្នាបានទាល់តែយល់គ្នា ។ ដើម្បីយល់គ្នាបានទាល់តែស្តាប់គ្នាឱ្យយល់គ្នាទៅវិញទៅមក ។ ដើម្បីនឹងស្តាប់គ្នាឱ្យយល់គ្នាទៅវិញទៅមកបានទាល់តែកុំឱ្យមានអ្វីដូចជាកំហឹងជាដើមមកខាខាំងរវាងគ្នា និងគ្នា។

បើយើងអង្គុយជាមួយគ្នាដើម្បីនិយាយគ្នាយើងត្រូវតែអាចមើលមុខគ្នាឱ្យចំ។ យើងទាំងអស់ដឹងថាគ្រាន់តែពាក្យសំដីមិនគ្រប់គ្រាន់ទេដើម្បីនឹងយល់គ្នាទៅវិញ ទៅមកឱ្យច្បាស់បានទេ យើងត្រូវសង្កេតមើលនូវកាយវិការថែមទៀត គឺតាំងពីមុខមាត់ភ្នែកដៃជើងជាដើម ។

ការយល់គ្នាទៅវិញទៅមកនេះធ្វើឱ្យងាយស្រួលក្នុងការជួយគ្នាទៅវិញទៅមក ។ ផ្ទុយទៅវិញការមិនយល់គ្នាទៅវិញទៅមកធ្វើឱ្យរាំងស្ទះក្នុងការជួយគ្នាទៅវិញទៅមក។

ខ្ញុំសង្កត់លើពាក្យ"យល់" ពីព្រោះពាក្យនេះជាពាក្យកន្លឹះសំរាប់ផ្តល់ការសម្រេចយកជោគជ័យក្នុងការនិយាយគ្នា។ ដូច្នេះក្នុងរឿងខ្ញុំនិយាយនេះពាក្យនេះមានន័យថា គោរពគ្នាទៅវិញទៅមកដឹងគំនិតគ្នាទៅវិញទៅមកយល់គ្នាទៅវិញទៅមកថាម្នាក់ៗនិយាយអំពីអ្វីដឹងការត្រូវការរបស់គ្នាទៅវិញទៅមកទាំងអស់គ្នាសុខចិត្តនឹងអ្វីៗដែលខ្លួនបានទទួល ទាំងអស់គ្នាពេញចិត្តនឹងអ្វីៗដែលខ្លួនបានទទួល និងដឹងទុក្ខធុរៈគ្នាទៅវិញទៅមកជាដើម។

តើយើងគួរជួយគ្នាទៅវិញទៅមកយ៉ាងណាដើម្បីឱ្យអ្នកមាននៅជាអ្នកមានឬមានឡើង ហើយឱ្យអ្នកក្រច្រើនឡើងច្រើនឡើងទៅជាអ្នកមាន ឬយ៉ាងតិចឱ្យអ្នកក្រច្រើនឡើងច្រើនឡើងចេញផុតពីភាពក្រីក្រ។

ខ្ញុំសុំជម្រាបជូននូវចំណុចខាងលើនេះនៅពេលក្រោយ

Mr. SosKem
Retired Foreign Service Officer
U.S. Department of State



"She tells me all the time
I'm so happy.
She loves being home with us."

CAREGIVER™ HOMES

Caregiver Homes™ helps elders and individuals with disabilities enjoy a high quality of life at home

- Pays & trains a full-time, live-in caregiver
- Provides professional support from a dedicated nurse and care manager
- Helps you find & access all necessary services

For more information, call 866.797.2333 or visit our website.
WWW.CAREGIVERHOMES.COM

- BEER
- WINE
- COFFEE

SOC TRANG
VIETNAMESE RESTAURANT

413 736-9999

113 VERMONT STREET. SPRINGFIELD, MA 01108




យើងមានសេចក្ដីរីករាយ និងសូមអញ្ជើញលោកអ្នកព្រមទាំងគ្រួសារ អញ្ជើញមកពិសារម្ហូបពិសេស ចំអិនដោយចុងភៅជំនាញរបស់យើង និងលំហែរកាយនៅសាលពិសារភោជនាហារ ដែលរៀបចំយ៉ាងប្រណិតសំរាប់ទទួលលោកអ្នក ។



ACCEPTING NEW PARTY BOOKINGS, ASSOCIATION MEETINGS, BIRTHDAYS ETC
200 PEOPLE CAPACITY.

ម្ហូបពិសេស

- មានហ្វើ -មានគុយទាវ -មានបាយស្រូប មានគ្រឿងក្លែម
- មានបំរើភេសជ្ជៈស្រាបៀ និងភេសជ្ជៈមានសុរាតិច

ទទួលកក់ពិធីជប់លៀង ឬ
ធ្វើការប្រជុំរបស់សមាគម ឬ
ធ្វើបុណ្យខួបកំណើត...
(ឱ្យខ្ចីសាលមិនគិតថ្លៃ _យកតែថ្លៃបំរើម្ហូប)

Open Monday-Sunday
9 a.m. – 9 p.m.
Closed Thursdays

SPECIALS:
*PHO * NOODLES *RICE COMBO
*SERVE BEER, LIGHT ALCOHOL DRINKS.


CAMBODIA
PHONE CARD
Veth Ratana
មិនកាត់នាទី និងមិនផុតកំណត់
សម្លេងឮច្បាស់ល្អទូរស័ព្ទទៅស្រុកខ្មែរ
4.5¢
per min
Bonus (10%) Min
$10.00 $1 224
$20.00 $2 448
$50.00 $5 1,122
$100.00 $10 2,244
Buy here and get 10% more!
Tel: (978) 942 1641/ (978) 656 8141
(267) 253 3947
www.cambodiaphonecard.us